# ការសំភាសន៍របស់អ្នកមីង ស្រី ជៀច

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ ស្រី ជៀប

## ការសង្ខេបរបស់អ្នកមីងស្រី ជៀច

អ្នកមីងស្រី ជៀច ជាអ្នកស្រុកស្អាង នៅកោះគរ ដែលកោះគរនេះគឺជាទីកន្លែងដែលប៉ុល ពតបានយកមនុស្សទៅសម្លាប់កាលពីជំនាន់ប៉ុល ពត ។ អ្នកមីងមានបងប្អូន៤នាក់ ប្រុសតែមួយទេ ក្រុមគ្រួសារអ្នកមីងជាអ្នកកសិករ ដែលបានដាំស្រូវនៅខែវស្សានឹងដាំបន្លែនៅរដូវប្រាំង!!! អ្នកមីងបានជួយក្រុមគ្រួសារក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតហើយអ្នកមីងថាពេលអត់មានអ្វីញ៉ាំគាត់ បានដាក់មងដើម្បីយកត្រីធ្វើម្ហូប ។ ឪពុកគាត់ក៏បានរត់ម៉ូតូឌុបដើម្បីចិញ្ចឹមគ្រួសារផងដែរ ។ យាយតាខាងម្តាយរបស់អ្នកមីងបានស្លាប់នៅជំនាន់ប៉ុល ពតដោយសារអត់មានអ្វីហូប តែគាត់បានទាន់ជីដូនជីតាខាងឪពុក
ហើយគាត់ប្រាប់ថាពួកគាត់ទាំងពីរនាក់សុទ្ធតែជាមនុស្សល្អស្លូតបូត។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិអ្នកមីងនៅក្នុងថ្ងៃនេះ ហើយពួកយើងសំភាសន៍នៅក្នុងខែមិនាឆ្នាំ២០១៨ ហើយពួកយើងសំភាសន៍គឺនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។
អ៊ីចឹងនាង់ខ្ញុំសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងដូចតទៅ
អ៊ីចឹងអ្នកមីងសូមប្រាប់ឈ្មោះពេញ ឈ្មោះអីគេ?

ខៈ ញ៉ុមឈ្មោះមីង ជៀច។

កៈចាំហ្នឹងហើយ!!

ខៈ ញ៉ុមជៀច ជៀប ព្រោះអត្តសញ្ញាបណ្ណ័គេសរសេរខុសហាំ!!

កៈឃើញនៅក្នុងសំបុត្រកំនើតគេហៅជៀប។ ជស្រៈៀនឹង ប។

ខ៖ ចាំហ្នឹង ហ្នឹងហៅដូចគេម៉ងទៅ។

ក៖ចាំហ្នឹងហើយ ដោយសារនៅក្នុងសំបុត្រកំនើតគេដាក់អញ្ចឹង។

ក៖ចាំ!!

ខ៖អ្នកមីងសព្វថ្ងៃមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ៥០ជាង ៥០ប៉ុន្មានទេ។

ក៖៥០ប៉ុន្មានមីង?

ខ៖ កើតឆ្នាំ១៩៧៣។

ក៖៧៣(១៩៧៣)?

ខ៖ ចាំគិតទៅអាយុប៉ុន្មានឆ្នាំញ៉ុមអត់ដឹងដែរ!!

ក៖ហ្នឹងហើយ ។

ខ៖ព្រោះញ៉ុមឧស្សាហ៍ភ្លេច។

ក៖អញ្ចឹងដឹងតែ៥០ជាងហើយសព្វថ្ងៃហ្នឹង?

ខ៖ ចាំ!!ហ្នឹងហើយដឹងតែ៥០ជាង ឆ្នាំឆ្លូវ១៩៧៣។

ក៖អ៊ីចឹងអ្នកមីងកើតឆ្នាំខ្មែរ១៩៧៣ហ្នឹងមីងណោះ?

ខ៖ចាំ!!

ក៖ចាំហ្នឹងហើយ អ៊ីចឹងឆ្នាំខ្មែរមីងកើតឆ្នាំអីគេ?

ខ៖ ឆ្នាំអីគេម៉ែ?

ក៖ ឆ្នាំឆ្លូវហើ?មិញនិយាយថាឆ្លូវហោ?

ខ៖ឆ្នាំឆ្លូវ ចង់ភ្លេច!!

ក៖ឆ្លូវហោ!!!អ៊ីចឹងអ្នកមីងសំរាប់អ្នកមីងមានទីកន្លែងកំនើតនៅឯណាវិញ?

ខ៖ ហ្នឹងហើយនៅហ្នឹង!!

ក៖មីងកើត!!

ខ៖នៅហ្នឹងហើយម៉ែ!!

ក៖មីងកើតនៅហ្នឹងហោ?

ខ៖ កើតហ្នឹងអីម៉ែ?

(ម្តាយរបស់គាត់)៖ កើតនៅហ្នឹង!!

ក៖កើតនៅហ្នឹងហោ!!អ៊ីចឹងមើលនៅក្នុងសំបុត្រកំនើតរបស់អ្នកមីងអ្នកមីងមានទីកន្លែងនៅភូមិកោះគរ ឃុំ រកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា។

ខ៖ចាំ!!

ក៖ចាំ!!អ៊ីចឹងអ្នកមីងកើតនៅក្នុងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៧៣!! ហ្នឹងហើយនៅកោះគរយើងហ្នឹង!!

ខ៖ចាំ!!

ក៖ចាំ!!សំរាប់អ្នកមីងអ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ មើល៤នាក់!!

ក៖៤នាក់ហោ?

ខ៖ ប្រុស១ហើយស្រី៣!!

ក៖ចាំ!!ស្រី៣?

ខ៖ចាំ!!

ក៖អ៊ីចឹងមីងជាកូនទីប៉ុន្មានវិញ?

ខ៖ ទី២។

ក៖ទី២ហោ?

ខ៖ចាំ!!

(ម្តាយរបស់គាត់)៖នេះ!!

ក៖ នេះសំបុត្រកំនើតរបស់អ៊ំហើយ របស់អ៊ំទាំងអស់ហោ!!អ៊ំបើមានអាកុបពីក៏ល្អដែរ បើសិនជាអត់ក៏អត់អីដែរ!!

(ម្តាយរបស់គាត់)៖ សំបុត្រកំណើតក៏មានដែរ!!

ក៖ ដូចរបៀបថាមីងសំបុត្រកំនើតសំបុត្រអីហ្នឹងទៅ របៀបថាទុកអោយមនុស្សជំនាន់ក្រោយអាចដឹងថាតើសម័យយើងើតលូវហ្នឹងថាសំបុត្រ អាបញ្ជីជាតិហ្នឹងធ្វើម៉េចៗអ៊ីចឹងទៅមីងណាស់!!អ៊ីចឹងដល់ពេលចតទៅគាត់ដឹងហើយ !!

ខ៖ចាំ!!

ក៖លោរថាថ្ងៃក្រោយទៅមានការផ្លាស់ប្តូររដ្ឋបាលដែនដីអីអញ្ចឹងហាំ ថាលោរគេធ្វើអីគេផ្សេងអ៊ិចឹងណាស់!! អ៊ីចឹងមីងមានបងប្អូនប្រុសស្រី៤នាក់អញ្ចឹងណោះ?

ខ៖ ស្រី៣ប្រុស១។

ក៖ ចាំ មីងជាកូនទី២!!

ខ៖ ចាំទី២។

ក៖មីងអើរបងប្អូនមីងគាត់ឈ្មោះអីគេខ្លះ?

ខ៖ ឈ្មោះអើរមីង ជ្រឹប ហើយហ្នឹងញ៉ុមមីងជ្រៀចហ្នឹង!!

ក៖ចាំ!!

ខ៖ហើយមីងចាន់ថា ហើយហ្នឹងអាន។

ក៖ហ្នឹង ពូអាន?

ខ៖ចាំ!!

ក៖ហ្នឹងបងប្អូនមីងទាំង៥នាក់ហ្នឹង?

ខ៖ចាំ!!

ក៖ត្រកូលស្រីទាំងអស់?

ខ៖ ត្រកូលហ្នឹងទាំងអស់។

ក៖ចាំ!!មីងពូកគាត់នៅណាវិញបងប្អូនមីងទាំងអស់?

ខ៖ នៅអើរ មីងជ្រឹបនៅខាងក្រោយនេះមួយ ហើយមីងថានៅថៃ ហើយប្អូនប្រុសញ៉ុមមួយនៅនេះ។

ក៖ចាំចុះអ្នកមីងនៅខាងក្រោយនេះ?

ខ៖ញ៉ុមនៅជាមួយម៉ែញ៉ុមតើ!!តែមីងជ្រឹបនៅក្រោយ!!ក៖ហ្ហំ!!ខ៖ផ្ទះគាត់បែកនៅខាងក្រោយ។

ក៖ចាំ!!អីចឹងមួយនៅថៃ មួយទៀតនៅខាងក្រោយ ២ទៀតនៅទីនេះ?

ខ៖ មួយនៅថៃមួយនៅក្រោយ ពីរនៅនេះ។

ក៖ចាំ!!បែងចែកគ្នា!! មីងមូលហេតុអីបានប្អូនអ្នកមីងគាត់ទៅថៃដែរ?គាត់ធ្វើអីគេវិញ?

ខ៖ ធ្វើការ ដូចថាខ្វះខាត!!

ក៖ចាំអញ្ចឹងដូចថាចំណាកស្រុកអីចឹងទៅមីងណោះ?

ខ៖ ចាំ!!

ក៖ ហើយទៅថៃគាត់ទៅធ្វើការខាងអីគេវិញមីង?

ខ៖ ទៅ!! អត់ដឹងខាងអីផង!!ម៉ែខាងអីគេទៅថៃចាន់ថា?

(ម្ដាយគាត់)៖ ខាងអេឡិចត្រូនិច។

ខ៖ ខាងអេឡិចត្រូនិច។

ក៖ស្រីសោះ?

ខ៖ ស្រី!!

ក៖ចេះធ្វើខាងអេឡិចត្រូនិចទៀត?

ខ៖ ចាំ!!ទៅប៉ុន្មាននាក់ហ្ន៎!! ទៅហ្នឹងបងប្អូននាំទៅ!!

ក៖ចាំ!!ដូចទៅហ្នឹងគាត់ទៅដោយស្របច្បាប់តើមីងណោះ?

ខ៖ ទៅដោយស្របច្បាប់!!មាន!!

ក៖មានប៉ាស់ស្ព័រមានអីអញ្ចឹងទៅណោះ?

ខ៖ ចាំ!!

ក៖ហើយបងគេអត់មានអាប៉ាស់ស្ព័រហ្នឹងវាដូចអត់កើតទេមីងណោះ?

ខ៖ ចាំ!!

ក៖ ចាំ អ៊ិចឹងមីងសំរាប់បងប្អូនមីងទាំង៥ហ្នឹងតើមីងចាំអីគេខ្លះពីពួកគាត់អ៊ិចឹងអនុស្សាវរីយ៍ដូចថារបៀបពីក្មេងមកពួកគាត់ធ្លាប់ធ្វើអីគេខ្លះអ៊ីចឹងណាស់?

ខ៖ ហ្ន៎!!ធ្វើស្រែចំការអីអញ្ចឹងទៅ។

ក៖ចាំ!!

ខ៖ធ្វើស្រែ។

ក៖ធ្វើតែស្រែទេអ៊ីចឹងហោ?

ខ៖ ធ្វើស្រែធ្វើបន្លែអីអញ្ចឹងទៅ!!

ក៖មើលមីងពីក្មេងមកធ្លាប់ធ្វើអីគេខ្លះជាមួយពួកគាត់?

ខ៖ ខ្ញុំហោ?

ក៖ចាំ!!

ខ៖ បើនិយាយទៅញ៉ុមរៀបរាប់រឿងអោយអស់តាំងពីញ៉ុមនៅក្មេងៗហាំ !!

ក៖ហ្នឹងហើយ និយាយអោយអស់មកអ្នកមីង?

ខ៖ បើនិយាយទៅតាមម៉ែញ៉ុមណាស់តាំងពីអាយុ៩ឆ្នាំញ៉ុមធ្វើស្រូវញ៉ុមលុយទឹកត្រឹមណោះ!!

ក៖ទឹកត្រឹមករ។

ខ៖ហើយញ៉ុមមើលគោអត់ដែលបានពេលណា!!

ក៖ចាំ!

ខ៖ចាំមើលហាម៉ែញ៉ុម
ទៅហើយណាស់គាត់ទៅចំការមុនហើយញ៉ុមទៅក្រោយដល់ម៉ោង១១ហ្នឹងញ៉ុមចេញទៅក្រោយទៅ
អញ្ចឹងទៅញ៉ុមមើលគោហើយមើលគោ៣ ៥អិចឹងទៅដើរតាមអូរអញ្ចឹងទៅណាស់
ហើយគោឆ្លងទឹកអូរអញ្ចឹងទៅហើយណោះទឹកត្រឹមហ្នឹងអីចឹងហិ!!!

ក៖ហ៊ើៗ!!

ខ៖តោងកន្ទុយគោអញ្ចឹងហិ!!ជួនកាលហ្នឹងគោធាក់មួយជើងអញ្ចឹងទៅ
ធាក់ក្នុងទឹកអញ្ចឹងទៅតែវាអត់អីទេណាស់!!

ក៖ចំ!!

ខ៖ហ្នឹងតោងកន្ទុយគោហែលទឹកអញ្ចឹង!!

ក៖មិនឆ្អល់ងាប់ហើយមីង?

ខ៖ វាធាក់ដែរ តែគ្រាន់តែថាវាធាក់តិច!!

ក៖វាកំលាំងទឹកហោ?

ខះ ចាំកំលាំងទឹកទេណាស់!!

កះចាំ!!

ខះហ្នឹងស្រាប់ដល់តែដល់ពេលហើយទៅដល់ ដល់គោកអ៊ីចឹងទៅវាដើរដល់មុខយើងដើរក្រោយអ៊ីចឹងទៅ!!

កះចាំ!!

ខះហើយយើងដល់ចំការអ៊ីចឹងទៅ ដល់ចំការហើយដើរមកវិញទៅហើយជូនកាលដល់ចំការដល់ទូលប្រសាទឆ្ងាយ!!យប់ម៉ោង៦ ៧មកដល់ផ្ទះក៏មានដែរ។

កះ ឃ្វាលគោ?

ខះ ឃ្វាលគោហាំ!!ហ្នឹង ស្រាប់ដល់ពេលហើយទៅធ្វើបន្លែ ធ្វើបន្លែទៅថាញ៉ុមមើលគោថាញ៉ុមដើរតាមផ្លូវទូលក្រសាំងហ្នឹងឡើងរិចជើងអស់ហើយនៅពីក្មេង។

កះហើយចុះបងប្អូនអត់ជួយមើលទេចុះ?

ខះ គេផែនការគេគេធ្វើផ្សេងគេស្ទូងស្រូវស្ទូងអីអញ្ចឹង!!

កះហ្អ៎!!

ខះខ្ញុំអ្នកដឹកគោ!!ដើរអញ្ចឹងទៅណាស់ ដើរទំរាំតែទៅដល់ចំការទៅដល់ចំការអញ្ចឹងទៅហូបបាយហូបអីអញ្ចឹងទៅបានចុះស្ទូងស្រូវស្ទូងអីអញ្ចឹងទៅបានចុះជញ្ជូនកណ្តាប់ជញ្ជូនអីអញ្ចឹងទៅពេលខែច្រូតអញ្ចឹងទៅលីកណ្តាប់លីអីអញ្ចឹងទៅ។

កះចាំ!!

ខះលីទៅផ្ទះអញ្ចឹងទៅ ហើយដល់ពេលហើយខែធ្វើស្រូវអញ្ចឹងហើយ ធ្វើបន្លែ!!

កះហ៊ឺ!!

ខះធ្វើបន្លែអញ្ចឹងទៅ បោចស្មៅបោចអីអញ្ចឹងទៅ ធ្វើស្មៅធ្វើអីអញ្ចឹងនៅចំការទៅ ២ ៣នាក់ហ្នឹងបោចស្មៅនៅចំការអីអញ្ចឹងទៅថាអត់មានពេលស្រួល!!

កះពេលសំរាក!!

ខះ ពេលសំរាកអីអញ្ចឹងទេ!!ជូនការងងុយដេកអញ្ចឹងទៅ ដេកខ្លះអីខ្លះអ៊ីចឹងទៅ ដេកខ្លះបោចខ្លះអីអញ្ចឹងទៅ បោចទៅដោយស្មៅ ដោយបន្លែអីខ្លះអញ្ចឹងទៅ!!ហ្នឹង!!

កះមីងដាំអីគេខ្លះទៅ?

ខះដាំអើរត្រូឆាយ ដាំស្ពៃចង្កឹះ ដាំឆៃថាវ។

កះស្ពីគេត្រូឆាយហ្នឹងមីង?

ខះ ត្រូឆាយហ្នឹងស្ពៃជ្រក់យើងហ្នឹង!!ហ្នឹង ហើយដាំបាយមួយកញ្ជើមួយកញ្ជើទូលទៅ។

កះទូលទៅ!!

ខះ ទូលទៅ ធ្វើស្រូវអញ្ចឹងទៅជួនកាល អត់មើលគោទេ ជួនកាលទូលបាយអញ្ចឹងទៅតាមម៉ែញ៉ុមអញ្ចឹង!!

កះចាំ!!

ខះធ្វើបន្លែធ្វើអីអញ្ចឹងទៅ ហ្នឹងហើយ!!

កះចាំអញ្ចឹងអ្នកមីងចេះតែធ្វើ!!

ខះ ធ្វើស្មៅធ្វើអីអញ្ចឹងទោអង្គិល ថានិយាយមួយថ្ងៃហ្នឹងក៏អត់អស់ដែរ!!

កះមើលនិយាយអោយអស់មក!!

ខះ ប្រវត្តិតស៊ូហ្នឹង និយាយថាពីធ្វើបន្លែហ្នឹង រែកទឹកទៀត រែកទឹកលោកអើយ សួរម៉ែញ៉ុមមើលហ្មរែកទឹកឡើងក្រិន គេចេះតែនិយាយទៅអញ្ចឹង គេថាអញ្ចេក!!

កះចាំ!!

ខះគេនិយាយថាអញ្ចេកហ៊ីមីងជ្រៀចឯងហាំរែកទឹកអញ្ចឹងឡើងក្រិនអស់ហើយ ខ្លួនតឿនអញ្ចឹងហើយ រែកទឹកទៀតរិតតែតឿទៀតក្រិនអស់ហើយ ថានិយាយមួយថ្ងៃអត់នេះទេ ញ៉ុម!!

(ម្ដាយគាត់)៖ កំសត់ណាស់ក្មួយអើយទំរាំបានប៉ុណ្ណេះ!!បងប្អូនគេធ្វើអោយទេផ្ទះនេះហ្នឹង!!

ក៖ចាំ!!

ខ៖ហើយផ្ទះនេះណាស់គេជួយធ្វើខ្លះហើយក្រៅពីហ្នឹងលុយញ៉ុមហើយមីងចាន់ថាទេក្មួយញ៉ុមហើយញ៉ុមអីហ្នឹងហាំ តស៊ូយកលុយរដ្ឋហាំ យកលុយរាប់ពាន់ធ្វើផ្ទះហ្នឹងហាំ!!

ក៖ចាំ!!

ខ៖ជំពាក់គេហាំ នៅសល់ជាង១០០០ទៀតទល់រាល់ថ្ងៃហ្នឹង!!

ក៖ ហាំ ក៏បានវែងឆ្ងាយល្អម្លេះមីង?

ខ៖ហ៊ីចេះតែយកបន្តមីអូន!!

ក៖ហ្វ៎ បណ្ដាក់គ្នា!!

ខ៖ យកបណ្ដាក់ហាំ អស់មួយបណ្ដាក់យកមួយបណ្ដាក់អញ្ចឹងហាំ!!

ក៖ហ៊ីៗ!!

ខ៖ហើយឥឡូវញ៉ុមយកចាក់ដីក្រោយជាង១០០០ទៀត។

ក៖ចាំ តែដីក្រោយវែងហ្នឹងរបស់មីងទាំងអស់ហ្នឹងមីងហោ?

ខ៖ ហ្នឹង របស់មីងទាំងអស់ហ្នឹង!!

ក៖តែអត់មានដាំអីអញ្ចឹងមីង?

ខ៖ មិនមែនរបស់មីងទេ ច្រឡំមាត់ ចែកគ្នាមួយនាក់បន្តិច មួយនាក់បន្តិច ។

ក៖ជាមួយបងប្អូនអីចឹងទៅមីងណោះ?

ខ៖ ជាមួយបងប្អូនហ្នឹង !! ហើយចាំមើលណាស់មីងច្រើបហ្នឹងចែកអោយគ្នា៤ ១០ ២០ម៉ែត្រអញ្ចឹងទៅណាស់ ។

ក៖ចាំ!!

ខះ ៤ ១០ ម៉ែត្រហើយញ៉ុម៤ ១០ម៉ែត្រ ហើយប្អូនញ៉ុមទៅណាស់អាប្រុសខ្លះហើយមីងចាន់ថាហ្នឹងខ្លះទៅ។កះហ៊ឺ១!!ខះហ្នឹងហើយ អាហ្នឹងយើងចែកគ្នាអញ្ចឹងទៅអាហ្នឹងយើងអត់!!

កះចាំហ្នឹងហើយត្រូវតែអញ្ចឹងហើយ ដោយសារបើមិនចែកបានធ្វើអីធ្វើផ្ទះធ្វើអីដាំអីទៅធ្វើអីអញ្ចឹងទៅណាស់!!

ខះថាប្រវត្តិតស៊ូអាយុជិត៥០ហើយ ជិត៥០ហើយ និយាយក៏អត់អស់ដែរ។

កះរៀងសង្ខេបរាងសំរាយអីចឹងទៅអ្នកមីងហាំ!!

ខះចាំ!! ប្រវត្តិតស៊ូនោះតាំងពីដើមមក ញ៉ុមមិនដែលបាននេះទេ!!

កះអត់ដែលបានស្រួលទេហេ?

ខះ អ់តដែលបានស្រួលទេញ៉ុម!!

កះ ចេះតែធ្វើការចំការ ចេះតែធ្វើអីអញ្ចឹងទៅអ្នកមីងណោះ?

ខះ ចាំធ្វើចំការរហូត !!

កះចាំ!!

ខះធ្វើចំការ ថ្ងៃណាក៏ធ្វើចំការ ថ្ងៃណាក៏ធ្វើចំការ!!ទឹមតែឥលូវដែលពេលញ៉ុមចូលសាសនាហ្នឹងទេ ម៉ែញ៉ុមលក់ដីអស់រលីង។

កះ ម៉េចបានលក់ដី?

ខះចុះប៉ាញ៉ុមឈឺក្រពះ ពោះវៀន ក្រពះ ពោះវៀន ដល់ពេលដីឡើងថ្លៃអត់មានដីលក់សោះ!!

កះចាំ!!

ខះតែអត់ទេអត់តាមយថាកម្មយើងដែលយើងបានដូចថាតាមផលបុណ្យយើងដែលផលបុណ្យយើង កំនត់យើងមកពីជាតិមុនអីទេណាស់។

កះហ៊ឺចាំ!!និយាយទៅវាអញ្ចឹងទៅហើយមីងណោះ?

ខះ ចា៎ តាមអញ្ចឹងទៅ!!

កះ ដោយសារបានដីហ្នឹងហើយបានបានប៉ាគាត់ជាគាត់អីអញ្ចឹងទៅណាស់។

ខះចា៎ បានបានប៉ាញ៉ុមជាបានបានរស់នៅមានជីវិតរស់នៅអីទៅណាស់!!

កះ បានបានមើលកូនមើលអី!!

ខះ ញ៉ុមអត់សូវចេះនិយាយទេ ញ៉ុមនិយាយចាំតែខ្លះៗហ្នឹង ដូចថាញ៉ុមវាភ្លេចៗអស់ហើយ

កះចា៎!! ចុះមីងចុះពេលនៅពីក្មេងៗភាគច្រើនចូលចិត្តលេងអីគេជាមួយបងប្អូនជាគេ?

ខះ លេងហេ?

កះចា៎!!

ខះលេងដូចថាលេងសើចលេងអីអញ្ចឹងទៅណាស់
ដូចថាលេងលោតអន្ទាក់លេងអីជាមួយគ្នាអញ្ចឹងទៅ!!

កះ ដល់ពេលបាយទឹកអញ្ចឹងទៅហូបជុំគ្នាអីអញ្ចឹងទៅណាស់!!

ខះ បាយទឹកអីហ្នឹងហូបជុំគ្នាអញ្ចឹងទៅណាស់ តែបងប្អូនញ៉ុមអត់ចេះឈ្លោះគ្នាទេ!!

កះហ្ន៎អញ្ចឹងស្រួល!!

ខះ អត់ចេះឈ្លោះគ្នាទេតាំងពីដើមមក!!

កះចា៎!!

ខះតែទឹមតែឥឡូវហ្នឹងដូចថាអើរដូចថាចានក្នុងរាវវាតែងមានរណ្ដំហើយ!!

កះ ទង្គិច!!

ខះវាមានទង្គិចហើយ!!

កះវាធម្មតា!!

ខះចាំ!!ហើយ ដល់ពេលហើយទៅ តែបងប្អូនញ៉ុមអត់ចេះគុម្គគួនគ្នាទេ!!

កះចាំ!!

ខះជជែកគ្នាដល់ពេលមួយពីរមួយពីរអញ្ចឹងដល់ពេលអ្នកណាខ្លាំងពេក ដូចថាខ្ញុំចិត្តទន់ បងប្អូនញ៉ុមអត់ចេះគុម្គគួនទេ ជជែកគ្នាហើយថ្ងៃហ្នឹងស្អែកឡើងត្រូវគ្នាហើយ!!

កះចាំ!!

ខះអត់ចេះគុម្គគួនគេទេខ្ញុំ!!

កះចាំដោយសារបងប្អូនពេលថ្ងៃក្រោយទៅមានការអីពឹងពាក់គ្នាទៅវិញទៅមក!!

ខះ ចាំ!!ពឹងពាក់គ្នាទៅវិញទៅមក!!

កះធ្វើកម្មវិធីអីឬក៏មានបុណ្យទានអីអញ្ចឹងទៅ ត្រូវតែទំនាក់ទំនងគ្នាមីងណោះ!!

ខះ ទំនាក់ទំនងគ្នា!!

កះ បើយើងប្រេះឆាគ្នាយើងមើលមុខគ្នាអត់ចំហាំ!!

ខះ ប្រេះឆាមើលមុខគ្នាអត់ត្រង់ទេ!!

កះហ្នឹងហើយវាពិបាក!!ដោយសារនៅលើផែនដីយើងហ្នឹងមនុស្សមិនអាចរស់នៅតែម្នាក់ឯងបានទេ!!

ខះចាំហ្នឹងហើយ!!

កះចាំអញ្ចឹងត្រូវតែមានដូចថា មានទំនាក់ទំនងល្អជាមួយគ្នា!!

ខះចាំ!! បងប្អូនញ៉ុមដូចថាមានជ្រើបអត់ដីអត់អីអញ្ចឹងអាកុងញ៉ុមមកអញ្ចឹង !!!

កះចាំ!!

ខះញ៉ុមចេះតែនិយាយប្រាប់កុងញ៉ុមអញ្ចឹងថា ដូចថាគាត់អត់អញ្ចឹងទៅ មាន២០រៀលអ៊ីចឹងទៅ !!

កះចាំ!!

ខះអញ្ចឹងញ៉ុមអានិតអានិតបងប្អូនអញ្ចឹងទៅ ហើយដូចថាបងប្អូនញ៉ុមដូចថាអត់ចេះគុម្ភគួន អត់ចេះឈ្លោះគ្នាបានយូរអត់ចេះជជែកគ្នាធំដុំអីទេ ដូចថា ដូចថាណាស់តែអ្នកដទៃទេណាស់តែមកចាក់អញ្ចេះចាក់អញ្ចុះ!!

កះមានអញ្ចឹងទៀត?

ខះ ចាំ!!

កះអញ្ចឹងពិបាកអញ្ចឹងទៀតណោះ?

ខះ ហ្នឹងហើយ!!មកទៅធ្វើអោយបងប្អូនយើងឈ្លោះគ្នាអញ្ចឹងទៅ!! ហើយវេទនាណាស់!!

កះ វេទនាម៉េចមីង?

ខះបង់ការប្រាក់!!រាល់ខែ !!

កះហ៊ឺ!!

ខះញ៉ុមប្រាប់ តាំងពីឆ្នាំអើរដូចថាធ្វើអីមួយអញ្ចឹងចេះតែអត់លុយអីអោយគេអញ្ចឹងទៅណាស់ !!

កះហ៊ឺៗ!!

ខះហើយដល់ពេលហើយទៅម៉ែញ៉ុមរកលុយអត់ទាន់អញ្ចឹងទៅធ្វើការធ្វើអីអញ្ចឹងទៅស៊ីឈ្នួលអីគេអញ្ចឹងទៅយកលុយសងគេទៅណាស់
ចងការគេបង់ការបង់អីអោយគេអញ្ចឹងទៅបង់ការប្រាក់គេរហូតហ្នឹង មកទឹមតែឥឡូវទេនេះបន្តិច!!

កះស្បើយតិចមីងហោ?

ខះ ស្បើយបន្តិច!!

កះចាំ!!

ខះតែគ្រាន់តែថាឥឡូវវានៅជំពាក់គេខ្លះដែរ ជំពាក់គេដូចថាត្រឹមជាង១០០០អីអញ្ចឹងទៅណាស់!!

កះចាំ!!

ខះមីងថានោះគាត់ជំពាក់គេផ្សេងមីងជំពាក់គេផ្សេង!

កះចាំអញ្ចឹងវាពិបាកអីចឹងដល់ពេលអើយ!!មីងចាន់ថាគាត់ទៅថៃមួយអីចឹងទៅ?

ខះ ទៅថៃមួយទៅ!!

កះចាំ!!អញ្ចឹងបានផ្ញើអីមកផ្ទះដែរតើមីងហេ?

ខះ អត់ទេទឹមទៅបានតែមួយខែទេ!!ទៅសារមុនបានមួយសារហើយ!!

កះតែគាត់មានប្ដីហើយតើហី?

ខះ នៅទេអត់ទាន់មានប្ដីទេ!!

កះហា???

ខះ អត់ទាន់មានប្ដីទេមីអូនអត់ទាន់មានទេ!!

កះហ៊ី!! អញ្ចឹងមីងមានអ្នកមីងម្នាក់បងស្រីម្នាក់គាត់នៅកោះគរយើងហ្នឹងដែរ គាត់ គាត់អត់ទាន់មានស្វាមីហ្ហ៎!! បងស្រីម្នាក់នោះហ្ហ៎!! ហេមីងចាន់ថាហ្នឹងទេហេ?

ខះ ហ្នឹងមីងចាន់ថាហ្នឹង!!

កះគាត់រៀងក្មេងហាំ?

ខះ ហ្នឹងហើយ ហ្នឹងហើយ ហ្នឹងហើយ!!

កះហ្ហ៎!!ហ្នឹងហើយ ហ្នឹងហើយ ចាំហើយ!!

ខះចាំ!!

កះ គាត់នៅរៀងក្មេងតែគាត់អត់ទាន់មានស្វាមីទេ!!

ខះចាំ!!

កះអូយចាំគាត់ហើយ ញ៉ុមនឹកគាត់ណាស់!!មិនគួរណាទៅសោះ!

ខះហ្នឹងហើយ គាត់សួររកដែរតើ!! គាត់ថានឹកវិហារដល់ហើយ នឹកអ្នកវិហារ ថាហ្អែងទៅវិញទៅ ទៅវិញទៅ ទៅទៅហាទៅទៅ ញ៉ុមដូចថាញ៉ុមនិយាយលួងលោមអញ្ចឹងទៅណាស់!!

កះចាំ!!

ខះទៅទៅ ទៅវិញទៅ ហើយបងស្រីញ៉ុមរាល់ដងញ៉ុមឧស្សាហ៍ដាស់តឿនគាត់ណាស់អោយទៅណាស់!!ទៅទៅ!

កះបងចាន់ថាគាត់រៀងសំដីដែរតើ!!

ខះ ចាន់ថាសំដីណាស់ សំដី។

កះចាំ!!អូយនឹក!!!ញ៉ុមអត់នឹកស្មានថាពួកគាត់ឈប់ទៅវិញអញ្ចឹងទេមីងណាស់!!ខះចាំ!!កះញ៉ុមចង់អោយពួកគាត់ដូចដើមវិញហ្នំសប្បាយ!!

ខះញ៉ុមចង់អោយពួកគាត់ដូចដើមណាស់ ដូចកាលមួយហ៊ឹកមុនហ្នំ!! ដល់ពេលទៅដូចថាគាត់ខ្វះខាត!!!អញ្ចឹងបានញ៉ុមនិយាយប្រាប់ថាជីវិតញ៉ុម ញ៉ុមតស៊ូឆ្អែតហើយ ឆ្អែតជាងស៊ីបាយទៀតណាស់ !ឆ្អែតណាស់!!តស៊ូណាស់ ពិបាកណាស់តែញ៉ុមវាអោយញ៉ុមដូចថាញ៉ុមតស៊ូដូចថាយើងជំពាក់លុយគេយើងខំតស៊ូ!!

កះចាំ!!

ខះ ញ៉ុមដាំ!!

កះអីចឹងបានអីសងគេ!!

ខះ ញ៉ុមដាំបន្លែ ញ៉ុមរែកទឹកអើយដល់ពេលរៀងនេះអញ្ចឹងទៅយកលុយរដ្ឋទិញម៉ាស៊ីនទិញអីបាញ់អញ្ចឹងទឹក និយាយថាសព្វ តស៊ូថានៅក្មេងៗតស៊ូឃ្វាលគោបានតែអំពៅមួយដើមហ្នឹងដើរទៅហើយ។

កះកាច់ហូបបណ្ដើរឃ្វាលគោបណ្ដើរហោ?

ខ៖ ញ៉ុមប្រាប់ទៅមិនមែនដូចក្មេងឥលូវទេ ក្មេងមួយហឹកខ្ញុំថាញ៉ុមតស៊ូណាស់ញ៉ុមប្រាប់ទៅហើយជិះកង់ហ៎ា ងើបតាំងពីម៉ោង១២យប់ធាក់កង់ទៅផ្សារដើមគរហ៎ា!!លក់ទៀតហ៎ា!!

ក៖ឆ្ងាយណាស់មីងណាស់?

ខ៖ ឆ្ងាយ!!ណាស់ហើយដល់ច្បារអំពៅទៀត!!

ក៖ពីនេះទៅហើយជិះកង់ទៅ?

ខ៖ចា៎!!ញ៉ុមសួរពួកម៉ាក់ញ៉ុមនេះកាម៉ុនហើយផុននៅភូមិថ្មីនេះញ៉ុមប្រាប់ទៅញ៉ុមងើបតាំងពីម៉ោង១២ យប់ហ៎ាហើយញ៉ុមទៅដេកផ្ទះគេនៅតាខ្មៅទៀត ទៅជួលផ្ទះគេនៅតាខ្មៅទៅស្នាក់នៅអោយវាទាន់ពេលទាន់វេលា ជួនកាលគេអត់យកលុយទៅគេថានៅចុះតែស្គាល់គេនៅជិតនេះទេណាស់ ហើយងើបទៅតាំងម៉ោង២យប់ទៅត្រូវជួលផ្ទះនៅណោះដេកម៉ោង២យប់ទៅលក់បន្លែទៀត!!

ក៖ហ៊ី!!

ខ៖ញ៉ុមប្រាប់ទៅថាប្រវត្តិញ៉ុមតស៊ូ បើនិយាយទៅ!!

ក៖ពិបាកម៉ងមីងហេ?

ខ៖ ហ្នឹងហើយ!!ងើបតាំងម៉ោង៤ទៀតទៅទិញល្ហុង មកពីលក់វិញហើយហ្នឹងហ៎ា!

ក៖ហ៊ី!!ទៅទិញធ្វើអីគេល្ហុង?

ខ៖ទៅទិញល្ហុងនៅក្រោមហ្ន៎!!នៅកំពង់កុងហ៎ា!!

ក៖ហើយយកទៅលក់នៅឯណាវិញ?

ខ៖ ទៅទឹកវិលទៅ នៅកំពង់កុងហ្ន៎ជិះកង់ទៅហ៎ា!!

ក៖គេយកធ្វើអីគេមីងល្ហុងគេយកធ្វើលក់បន្លែធម្មតា?

ខ៖ គេលក់យកធ្វើសាច់គោអាំងធ្វើនំប៉ុងដាក់សាច់អីអញ្ចឹងទៅណាស់!!ខ៖ចា៎!

កៈអញ្ចឹងពីក្មេងមកធ្វើអញ្ចឹងម៉ងអ្នកមីងណោះ?

ខៈហ្នឹងហើយធ្វើអញ្ចឹងថាសួរម៉ែញ៉ុមមើលពិបាកណាស់!!

កៈអ្នកណាគេឈ្មោះម៉េង ស្រី?ប៉ាប៉ាហោ?

ខៈប៉ាញ៉ុម!!

កៈចាំអអញ្ចឹងសំរាប់បងប្អូនអ្នកមីងអ្នកមីងចាន់ថាបងប្អូនរបស់អ្នកមីងគាត់កើតឆ្នាំ១៩៧៨ ញ៉ុមមីងចាន់ថាកើតនៅពេលសង្គ្រាម?

ខៈ ចាំ !!

កៈកើតនៅពេលកំសត់។

ខៈ កើតនៅពេលហ្នឹងហោម៉ែពេលហ្នឹង?

(ម្តាយរបស់គាត់)៖ កើតនៅពេលសង្គ្រាមហ្នឹង!!

កៈហ្នឹងហើយក៏ពោះធំពេលនៅក្នុងសង្គ្រាម?ខៈចាំ!!

(ម្តាយរបស់អ្នកមីង)៖ ហ្នឹង កំសត់ណាស់ក្មួយអើយ!!កញ្ជើញសារ៉ុងពោះប៉ុនកញ្ជើរគ្រប់ខែហាំ!!

កៈចាំ!!

(ម្តាយរបស់អ្នកមីង)៖កញ្ជើរទៅ
ហើយគោពីរបីទៀតនៅតាមក្រោយដឹកមុនគេលឿនធ្វើមេទ័ពមុនគេមនុស្សរាបរយនាក់ញ៉ុមទៅមុនគេបង្អស់។

កៈចាំ!!

(ម្តាយរបស់អ្នកមីង)៖ទៅបន់ដូនបង់តាកុំអាលអោយខ្ញុំឈឺពោះចាំទៅដល់ស្រុកគេជីដូនជីតាម៉ែឪអើយ គ្រូបាតជាយអើយចាំញ៉ុមដល់ភូមិវិញចាំឈឺពោះចុះ !!

កៈចាំ!!

(ម្ដាយអ្នកមីង)៖មីនាងអើយកាត់ព្រៃកាត់ផ្សៃងសុទ្ធតែត្នោតព្រោកប្រាកៗមួយយប់ទល់ភ្លឺ ទៅដល់ទៅដល់ជិតកោះធំហ្នំទៅជិតដល់សំប៉ាន់ហាំ!!

កះចាំ!!

(ម្ដាយរបស់អ្នកមីង)៖មីងនាងឯងគ្រាន់តែថាចងគោហើយល្ងាចម៉ោង៤ ម៉ោង៥គេចែកបាយគេចែកបាយម្នាក់មួយកញ្ចប់ហាំអោយម្នាក់មួយកញ្ចប់ហើយតាំង
ហូបបាយហើយអីហើយដុតចង្កៀងហើយណាស់!!

កះចាំ!!

(ម្ដាយអ្នកមីង)៖ ស្រាប់ប្រាសដេក ប្រាសដេកទៅឈឺពោះឆាវ ឈឺពោះឆេវម៉ងគ្រូបាតជាយអើយម៉ែពុកអើយញុំមមកដល់ស្រុកគេហើយមិនដឹងកន្លែងមិនដឹងទីនៅឯណាជ្រកកោនទេ វាមិនទាន់មានផ្ទះមានសម្បែង ក៏បាត់ឈឺសិន!!

កះហ៊ីៗ!!

(ម្ដាយអ្នកមីង)៖ គ្រាន់តែគេថាព្រលឹមឡើងបញ្ជូនយាយហើយតាហ្នឹងគ្រួសារ៦៧នាក់ហ្នឹងផ្អាកសិនកុំអាល ដល់នេះម៉ែក្មេកញុំមក៏ថា ហ៊ីក្មួយអើយកូនញុំមវាឈឺពោះដើរអត់រួចទេ!!ហ៊ីអញ្ចឹងយាយនៅហ្នឹងចុះគ្រួសារហ្នឹង!!

កះចាំ!

(ម្ដាយរបស់អ្នកមីង)៖ មីនាងឯងយប់បន្តិចកើត។

កះកើតមីងចាន់ថា?

(ម្ដាយរបស់គាត់)៖ កើតនេះ។

ខ៖ កើតខ្ញុំហោ?

(ម្ដាយរបស់អ្នកមីង)៖ កើតវាហ្នឹងហ៎!!

កះកើតមីងជ្រៀចអាហ្នឹងកើត១៩៧៣ហ្នឹង!!!

(ម្ដាយរបស់អ្នកមីង)៖ ហ្នឹងហើយ!!

ក៖ អញ្ចឹងអ៊ំពេលហ្នឹងពេលនៅឆ្លងទន្លេមិនមែននៅក្នុងជំនាន់ប៉ុល ពតផងហ្នឹង លន់ នល់តើ!!

(ម្ដាយរបស់អ្នកមីង)៖ ហ៊ីលន់ នល់អី ប៉ុល ពតគៀរយកទៅ!!

ក៖ហាដោយសារមីងជ្រៀចគាត់កើត
គាត់ដាក់នៅក្នុងសំបុត្រកំណើតគេដាក់១៩៧៣!អ៊ំហាំតែ៧៣(១៩៧៣)នៅក្នុងលន់នល់ហ្នឹង!!

(ម្ដាយរបស់អ្នកមីង)៖ ប៉ុល ពតមកគៀរយកទៅ មុនដំបូងផ្ទះញ៉ុមនៅហ្នឹងហិ ដល់ពេលហើយញ៉ុមដាំបន្លែនៅក្រោយហ្ន៎!!

ក៖ចាំ!!

(ម្ដាយរបស់អ្នកមីង)៖វាគៀរញ៉ុមទៅផ្ទះ៩ ១០ហ្ន៎!!

ក៖ហ្ន៎ប្រហែលជាពេលហ្នឹងមានសង្គ្រាមអីខ្លះៗអីអញ្ចឹងទៅណាស់!!

(ម្ដាយរបស់អ្នកមីង)៖ សង្គ្រាម ហ៊ីគៀរអ្នកស្រុកយកអស់រលីង ញ៉ុមបែកបងប្អូនញ៉ុម១០នៅតែបងប្អូនខ្ញុំមួយទេណាស់!!

ក៖ចាំចាំមើលតិចទៀតសំភាសន៍អំពីជីវិតរបស់អ៊ំទៀត!! តែពេលហ្នឹងហាំ ពេលអ៊ំនៅក្នុងជំនាន់ប៉ុល ពតមានកូនប៉ុន្មាននាក់?ពេលឆ្លងទន្លេពេលនៅក្នុងប៉ុល ពតហាំ?

(ម្ដាយរបស់អ្នកមីង)៖ ពេលនៅក្នុងប៉ុល ពតហ្នឹង ខ្ញុំមានតែម៉ែ ម៉ែ!! មីងច្រឹបហ្នឹង។

ក៖ចាំ!! ប៉ុន្តែកើតហាំ ឆ្លងទន្លេនៅក្នុងប៉ុល ពតហ្នឹងអ្នកណាគេ?

(ម្ដាយរបស់អ្នកមីង)៖ ប៉ុល ពតហ្នឹងវាហ្នឹងហិ!!

ក៖ មីងជ្រៀច?

(ម្ដាយអ្នកមីង)៖ មីងជ្រៀចហ្នឹងហិ!!

ក៖ហើយដល់ពេលអ្នកមីងចាន់ថា?

(ម្តាយរបស់អ្នកមីង)៖ មីងចាន់ថាអាហ្នឹងកើតហើយហើយហ្នឹង កើតនៅក្នុងប៉ុល ពតហ្នឹងហើយហើយ!!

ក៖ហាអញ្ចឹងនៅក្នុងថ្ងៃខែឆ្នាំកំនើតនេះខុស!!គេដាក់៧៨(១៩៧៨)!!

(ម្តាយរបស់អ្នកមីង)៖ អញ្ចឹងក្នុងហ្នឹងគេដាក់ឈ្មោះអ្នកណា?

ខ៖ចាន់ថា!!

ក៖មីងចាន់ថា។

(ម្តាយរបស់អ្នកមីង)៖ គេមានខែមានថ្ងៃទេ ហ៊ីអត់ខុសទេ!!

ក៖ ហាដោយសារអញ្ចេកបើអ៊ំឆ្លងទន្លេអ្នកមីងចាន់ថានៅក្នុងជំនាន់ប៉ុល ពតត្រូវតែបើសិនជាឆ្លងទន្លេរបស់មីងនៅក្នុងលន់ នល់ បានត្រូវដោយសារនៅក្នុងសំបុត្រកំណើត!!

(ម្តាយរបស់អ្នកមីង)៖ អត់ទេ!!

ក៖នៅក្នុងនេះផ្សេង!!

ខ៖ អត់ទេ អញ្ចឹងមីអូនឯងមើលឈ្មោះមីងចាន់ថាទេហី?

ក៖ហ្នឹងហើយមីងចាន់ថា។

ខ៖ ចាំ!!

ក៖ មីងចាន់ថាអ៊ំស្រីឆ្លងទន្លេគាត់នៅក្នុងប៉ុល ពតហាំ!!អានេះ៧៨(១៩៧៨) ៧៨(១៩៧៨)មិនប៉ុល ពតហេ!!

ខ៖ អ៊ីចឹងនៅក្នុង៧៨(១៩៧៨)នៅក្នុងប៉ុល ពតម៉ែហេ?

ក៖ហ្នឹងហើយ!!

ខ៖ ហ្នឹងហើយសួរញ៉ុម!!

ក៖អញ្ចឹង អញ្ចឹងមីងកើតនៅក្នុង១៩៧៣ នៅក្នុងរាជលន់ នល់ហ្នឹង !!

(ម្តាយរបស់អ្នកមីង)៖ មិនមែនទេ! ប៉ុល ពតមកឡើងណែនភូមិណែនស្រុក ស្ងាត់ដូចចោរលួចសេះ!!

កៈ ហ្នុំអញ្ចឹងនៅក្នុងសំបុត្រកំនើតនេះខុសហើយហ្នឹង?

(ម្ដាយរបស់អ្នកមីង)៖ ចាំ!!

ខៈ អើយម៉ែ ខ្ញុំអើយកើតនៅ១៩៧៣ហ្នឹងនៅក្នុងអាពតទេហេ?

កៈអត់ទេនៅក្នុងលន់ នល់។

ខៈ ហ្នឹងហើយនៅក្នុងលន់ នល់ហ្នឹង។

(ម្ដាយរបស់គាត់)៖ អត់លន់ នល់ទេមីអូនអត់ទេ!!ប៉ុល ពតមកគៀរាប់ពាន់រាប់ម៉ឺននាក់ហ្នុំ!!

ខៈ ហ្នឹងហើយ បែបកនៅក្នុងអាពតហើយព្រោះអី១៩៧៣ហ្នឹងហាំ!!

កៈ ៧៣(១៩៧៣)លន់ នល់ហេ!!

ខៈអញ្ចឹងញុំមអត់ដឹងដែរ។

កៈចាំមើលអញ្ចេកពីលន់ នល់ ៧០(១៩៧០)ដល់៧៥(១៩៧៥)អាហ្នឹងលន់ នល់ ពេញហើយហ្នឹងហាំ ហើយមីងមិនកើតនៅក្នុង៧៣(១៩៧៣)វាមិននៅក្នុងរាជលន់ នល់!!ហើយដល់ពេល៧៥(១៩៧៥)ដល់!!៧៩(១៩៧៩)ហ្នឹងអាហ្នឹងប៉ុល ពត!!

ខៈ ហ្នឹងប៉ុល ពតហ្នឹងហេ?

កៈចាំ!!

ខៈ អញ្ចឹងនៅក្នុងប៉ុល ពតហើយលន់ នល់ហ្នឹងផ្សេងគ្នា?

កៈ ផ្សេងគ្នា!!ចាំដោយសារប៉ុល ពតជាពេលដែលសម្លាប់ខ្លាំងដល់ពេលលន់ នល់ អាពេលដែលគ្រាប់ផ្លោងកំពុងតែផ្លោងច្រើនហ្នុំ!!

ខៈ អញ្ចឹងហេ?

កៈហ្នឹងហើយ អញ្ចឹងទៅវា តែនៅក្នុងសំបុត្រកំនើតអ្នកមីងកើតនៅក្នុងឆ្នាំ១៩៧៣!!

ខៈចាំ!!

កះនៅថ្ងៃទី០៥ខែកក្កដាហ្នឹង!!ហ្នឹងបើយកតាមសំបុត្រកំណើត!!អ្នកមីង!អូខេចប់បងប្អូនហើយចូលដល់ម្ដាយម្ដង ម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរ?

ខះម្ដាយខ្ញុំ?

កះចាំ!!ឈ្មោះពេញ?

ខះ ឈ្មោះសួស យ៉ាត !!សួសយ៉ាតអញ្ចឹងម៉ែហី?

កះ ហ៊ីអត់ស្គាល់ឈ្មោះម៉ែខ្លួនឯងមីង!!

ខះ ខ្ញុំអញ្ចេកភ្លេចមុខភ្លេចក្រោយអត់ដូចពីមុនទេ ញ៉ុមអត់ដូច!!ញ៉ុមភ្លេចមុខភ្លេចក្រោយ!!

កះហ្នឹងហើយ ចាំ អញ្ចឹងម្ដាយអ្នកមីងគាត់ឈ្មោះសួស យ៉ាតនៅក្នុងសំបុត្រកំនើតបានបញ្ជាក់អញ្ចឹងគាត់កើតនៅក្នុងថ្ងៃទី០៤ខែមិថុនាឆ្នាំ១៩៤៥!!

ខះចាំ!!

កះនៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា។

ខះចាំ!!

កះ ចាំ!!អញ្ចឹងអ្នកមីងគាត់កើតឆ្នាំខ្មែរគាត់កើតឆ្នាំសត្វអីគេវិញ?

ខះ សត្វហេ?

កះចាំ!!

ខះឆ្នាំរកាគាត់។

កះចាំ!!

(ម្ដាយរបស់អ្នកមីង)៖ ឆ្នាំរកា។

កះចាំអ៊ំកើតឆ្នាំរកា។

ខះ ចា!!ញ៉ុមចាំឆ្នាំគាត់។

កះហ្នឹងហើយ អញ្ចឹងសំរាប់អ្នកមីងអ្នកមីងចងចាំអីគេខ្លះពីម៉ែ អ្នកមីងរៀបរាប់ពីចរិករបស់ម៉ែបន្តិចមើល?ហើយជួយមីង ហើយមើលថៃទាំមីងតាំងពីក្មេងមកម៉េច មកបាររៀងមកអោយអស់មក?

ខះ ដូចថាគាត់អើរមើលថៃទាំយើងអញ្ចឹងទៅណាស់ មើលថៃបាយទឹកអីអោយយើងអញ្ចឹងទៅហើយសំលៀកបំពាក់អីអញ្ចឹងទៅណាស់!!!

កះចាំ!!

ខះហ្នឹងអញ្ចឹង។

កះ ហ្នឹងហើយ!!

ខះ ហើយគាត់ខំរកស៊ីរកអីអញ្ចឹង ជួយកូនចៅអីអញ្ចឹងទៅណាស់!!

កះ ចាំ គាត់ប្រកបមុខរបរអីគេដែរ ដើម្បីចិញ្ចឹមមីងតាំងពីក្មេងមក?

ខះ តាំងពីក្មេងមកធ្វើស្រូវប្រាំង ធ្វើស្រូវប្រាំងជាមួយញ៉ុមហ្នឹង !!

កះចាំ!!

ខះ ធ្វើជាមួយគ្នាហ្នឹង ធ្វើស្រូវតាំងពីញ៉ុមដឹងក្តី ញ៉ុមទូលបាយរហូតសក់ក្បាលញ៉ុមចង់ជ្រុះហើយអស់ហើយសក់ក្បាលញ៉ុមនេះ ដើរឆ្ងាយណាស់ មិនមែនតិចគីឡូទេដឺ!!

កះហ៊ី!!

ខះនៅទួលប្រាសាទកន្លែងគេបូមខ្សាច់ហ្នឹង។

កះចាំ!!

ខះហើយចុះមកក្រោយហើយចុះឆ្ងាយមកអញ្ចេក ចុះមក!!!

កះដីនៅហ្នឹងសំបូរហ្នឹងហោ?

ខះ ដីនៅហ្នឹងតែដីញ៉ុម២ ៣ហិចតា!!

(ម្តាយរបស់អ្នកមីង)៖ តែប្តីឈឺលក់អស់ហើយ!!

ខ៖ហ្នឹងកុំតាឈឺហ្នឹង!!

ក៖ តែដីហ្នឹងត្រូវប៉ានខ្លាំងណាស់ឥឡូវហ្នឹង!!

ខ៖ ហ្នឹង ហ្នឹងត្រូវប៉ាន់ តែដូចថាយើងវាអត់មានសម្តាយបុណ្យ!!

ក៖អូយធំណាស់ អ៊ំ៥ហិចតាហាំ!!

ខ៖ ៥ហិតតាដីញ៉ុម។

ក៖ តែដោយសារតែឪពុកឈឺហ្នឹងក៏លក់ដីហ្នឹងទៅអស់ទៅមីងណោះ?

ខ៖ ចាំលក់ដីអស់ ចាំ!!

ក៖ មីង មើលចាំមើលធ្វើស្រូវប្រាំង !

ខ៖ ធ្វើស្រូវប្រាំង។

ក៖ ជីវិតរបស់អ៊ំធ្វើស្រែចំការហើយធ្វើអីគេទៀត?

(ម្តាយរបស់អ្នកមីង)៖ ធ្វើតែស្រូវហ្នឹង!!

ខ៖ធ្វើតែស្រូវហ្នឹង!!

ក៖ធ្វើស្រូវ!!

ខ៖ ធ្វើស្រូវហើយដាំបន្លែទៀតម៉ែ!!

ក៖បន្លែ!!

ខ៖ដាំបន្លែទៀត ម៉ែឯងភ្លេចហើយ!!

ក៖ បន្លែដាំបន្លែអីគេខ្លះ?

ខ៖បន្លែស្តែចង្កឹះដូចញ៉ុមរ៉ៃរ៉ាប់តាំងពីមុនមកអញ្ចឹង!!

កៈចាំ!!

ខៈស្តេចង្គឹះ ពូហ្សូនអីអញ្ចឹងទៅ!!

កៈ អីគេពូហ្សូនហ្នឹងមីង?

ខៈ ពូហ្សូនហ្នឹងស្ដេក្រញាញ់ ។

កៈ ហ្អ!!គេហៅពូហ្សូន?

ខៈចាំ!!

កៈត្រសក់អីអញ្ចឹងទៅណោះ?

ខៈ ត្រសក់ ខាត់ណាឈើអីអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈថាដាំខ្មេច ដាំខ្ទីអស់ហើយ។

កៈ ឥឡូវទៀត រៀបរាប់ពីចរិកម៉ែតិចមើលកាច់ស្លូតអីវ៉ាន់?

ខៈ ម៉ែញុំមហោ?

កៈ និយាយកុំអោយគាត់លឺ!!

ខៈ ម៉ែញុំមគាត់ដូចថាគាត់ដូចថាធម្មតាគាត់មានកាចគាត់មានស្លូត!!

កៈចាំ!!

ខៈអ៊ីចឹងមានតែអញ្ចឹង មានអញ្ចឹង មានកាចមានស្លូតអញ្ចឹងហើយម្ដាយឪពុកមិនមែននេះ!!

កៈ មិនមែនធម្មតារហូតទេ!!

ខៈធម្មតាអ៊ីចឹង!! មិនដែលស្លូតរហូតហើយក៏មិនដែលកាចរហូតដែរ មិនដែលស្លូតរហូតដែរ ធម្មតាអាហ្នឹងវាស្មើគ្នា!!

កៈចាំ
អញ្ចឹងអ្នកមីងសំរាប់រស់នៅជាមួយម្ដាយនិយាយទៅតាំងពីកើតមករស់នៅជាមួយគាត់រហូតអត់ដែលបែកម៉ងហើយទេហេ?

ខៈអត់ដែលបែកទេ ញ៉ុមរកចិញ្ចឹមម៉ែញ៉ុមរហូតទល់ដល់សព្វថ្ងៃ!!

កៈចាំ!!

ខៈយកលុយគេយកលុយរដ្ឋម្ដង៤០០០ដុល្លារ!!

កៈ ហើយយកច្រើនទៀត?

ខៈ ៤០០០ដុល្លារយកមកសងគេឥលូវលួសៗអស់ហើយ តែឥឡូវគាត់អត់ជំពាក់គេទេណាស់ !!

កៈចាំ!!

ខៈតែញ៉ុមជំពាក់គេវិញ យកលុយមកចាក់ដីជាង១០០០ដុល្លារ ហើយចាន់ថាក៏ជំពាក់គេដែរ។

កៈហើយចុះមីងចាន់ថាគាត់ជំពាក់គេស្អីគេដែរបើគាត់នៅក្រមុំហ្នឹងហេ?គាត់ធ្វើអីគេវិញមីង?

ខៈ ដូចថាអញ្ចេក ដូចថាគាត់ទិញនេះទិញនោះអីអញ្ចឹងទៅណាស់ ខ្ចីលុយគេអញ្ចឹងទៅណាស់!!

កៈ ទិញនេះទិញនោះអញ្ចឹងទៅចេះតែអញ្ចឹងទៅ!!

ខៈធ្វើនេះធ្វើនោះអីអញ្ចឹងទៅ!!គាត់អត់គាត់អីអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈជួយតាឈឺអីអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈហើយប៉ាញ៉ុមឈឺហ្នឹងហើយញ៉ុមជំពាក់គេអញ្ចឹងជួយគាត់ឈឺអីអញ្ចឹងទៅជួយទិញថ្នាំទិញអីយកមកចាក់អញ្ចឹងទៅ!!

កៈហ្អ៎!!

ខះទិញថ្នាំទិញអីយកមកអោយគាត់លេបអញ្ចឹងទៅ ហូបអញ្ចឹងទៅ!!

កះចាំ!!អញ្ចឹងអ្នកមីងចាន់ថាគាត់កើតនៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៧៨ប្អូនមីងហ្នឹងនិយាយដល់គាត់ក៏និយាយពីថ្ងៃខែឆ្នាំកំណើតរបស់គាត់អោយហើយ!!

ខះ ហើយក៏ជួយបង់លុយរដ្ឋបង់លុយអីអានិតគាត់ ហើយលោកអើយវេទនាណាស់ខ្ញុំហ្នឹងតែទឹមតែឥឡូវហ្នឹងដូចថា១០អីនៅធូ ហ្នឹងដូចថានៅសល់តែ៥អីអញ្ចឹងទៅណាស់៥!!

កះ ដូចទឹមតែពានពាក់កណ្តាលទេមីងហេ?

ខះទឹមបានពាក់កណ្តាល អត់ទេនៅទៀតអត់ទាន់នេះទេ អត់ទាន់ដាច់ស្រេចទេ!!

កះនៅតែ!! ចុះដីនៅក្រោយមិនព្រមដាំផ្ទីដាំអីទៅ?

ខះ ដាំផ្ទីហ្នឹងដាំអត់កើតទេ !!

កះហើយចុះបូមពីទន្លេអត់កើតទេហេ?

ខះ បូមហ្នឹងត្រយោរជាមួយចិនតែថ្ងៃណាវាបើកបើកទៅថ្ងៃណាវាអត់អត់ទៅ!! !!

កះហ្ហ៎!!

ខះ ហ្នឹងពិបាកណាស់ មិនមែនស្រួលទេ!!

កះ ចាំនិយយាអ៊ីចឹងពិបាកមួយមីងគឺរឿងទឹកហ្នឹងម៉ងមីងណោះ?

ខះ ចាំ បើយើងមានលុយញ៉ុមបុកអណ្តូងហើយតែញ៉ុមវាអត់លុយ!!

កះ ហ្ហ៎!!

ខះអត់លុយបុកអណ្តូង!!តាំងពីទឹក កុំអីក៏ញ៉ុមមិនដាំចេកដែរ!!

កះចាំ!!តែឃើញពួកគាត់អីឃើញដាំផ្ទីបានច្រើនណាស់មីងណាស់!!!

ខះ ដាំផ្ទីដាំអីបាន!!ដាំផ្ទីដាំអីបានច្រើន!!!តែញ៉ុមវាដាំអត់បានអត់ទឹកអត់អីអញ្ចឹងទៅណាស់ដល់ហើយញ៉ុមដាក់ចេកដាក់អីអញ្ចេកទៅណាស់!!

កៈចាំ !!តែមើលដីនៅនេះមើលទៅដាំបានអីបានដែរហ្នឹងហាំ!!

ខៈដាំបានតើ!!

កៈពួកគាត់កាត់បានម្ដងៗច្រើនៗគីឡូណាស់!!

ខៈដីឥដ្ឋ!

កៈងាប់ហើយទៅចាក់ដីចំដីឥដ្ឋទៀត!!

ខៈ ហ្នឹងចាក់ចំដីឥដ្ឋទៀត ញ៉ុមនឹកឃើញថាចាក់ដីទៅដូចថាញ៉ុមឃើញក្មួយញ៉ុមហ្នឹងហាំ!!ឃើញដើរក្លួកៗហើយខ្លាចពស់វាអីខាំអីវាហ្នឹងហាំ!!!

កៈហ៊ីៗ!!

ខៈអញ្ចឹងបានញ៉ុមយកលុយរដ្ឋយកមកចាក់ដី។

កៈចាំ!!

ខៈហើយដូចថាឃើញបងប្អូនញ៉ុមអីឃើញដូចថាដើរទៅក្រោយទៅអីអញ្ចឹងហើយម៉ែញ៉ូមហើយប៉ាញ៉ុមអីហ្នឹងគាត់ចង់ដើរទៅក្រោយអីអញ្ចឹងទៅអោយចាក់ដីទៅយើងកុំនៅខ្វង ហើយគេគេខ្ពស់អស់គេណោះខ្ពស់អស់គេណោះខ្ពស់អស់ខ្ពស់សងខាងហើយយើងភ្លៀងមកទឹកដក់ត្រឹមៗហ្នឹងហិ!!។

កៈហ្ហ៎ !! វាអត់បង្ហូរទៅណាស់ផង!!

ខៈចាំហ្នឹង ដល់ហើយញ៉ុមចាក់ដីទៅ ទ្រាំទៅ ទ្រាំនេះទៅណាស់ទ្រាំពិបាកអញ្ចឹងទៅ!!

កៈអញ្ចឹងទៅ?

ខៈ ទ្រាំយកលុយរដ្ឋ លុយអីយកមកចាក់ដីអញ្ចឹងទៅ!!

កៈអញ្ចឹងអ្នកមីងចូលដល់ឪពូកអ្នកមីងវិញម្ដង!! ឪពុកអ្នកមីងគាត់ឈ្មោះអីគេដែរ?

ខៈ ម៉ី ស្រ៊ី!! ម៉ី ស្រ៊ីម៉ែណោះ!!

កៈ ចាំហ្នឹងហើយ!!ហ្នឹងហើយ នៅក្នុងសំបុត្រកំនើតបានដាក់ដែរ ថាឪពុកឈ្មោះម៉ី ស្រ៊ី!!

ខៈចាំ!!ម៉ី ស្រ៊ី!!

កៈចាំអញ្ចឹងឪពុក របស់អ្នកមីងគគាត់កើតនៅក្នុងថ្ងៃទី០៥ខែ កក្កដា ឆ្នាំ១៩៤៥!!

ខៈចាំ!!

កៈ អញ្ចឹងឪពុកប្អូនរបស់ម្តាយមួយឆ្នាំ?

ខៈចាំ!!

កៈចាំ!!អញ្ចឹងគាត់កើតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា។ ចាំ!!អ្នកមីងចាំអីគេខ្លះពីឪពុកថាគាត់មានចរិកម៉េចដែរហើយ តើជីវិតរបស់គាត់ ថាតើអ្នកមីងធំដឹងក្ដីមកគាត់ម៉េចដែរអញ្ចឹងហាំ??

ខៈ គាត់ អើយ តាំងពីញ៉ុមដឹងក្ដីមកគាត់ធ្វើស្រូវធ្វើអីជាមួយញ៉ុមអញ្ចឹង!!!

កៈចាំ!!

ខៈ តាំងពីញ៉ុមទៅជាមួយគាត់នៅទូចៗ គាត់បណ្ដើរញ៉ុមទៅធ្វើស្រូវ ញ៉ុមទៅលីកណ្ដាប់លីអីជាមួយគាត់ទៅណាស់!!

កៈហ៊ឺៗ!!

ខៈបោកបែនជញ្ជូនធ្វើស្រូវប្រាំងហើយធ្វើស្រូវវស្សា ប៉ាហាំប៉ាញ៉ុមធ្វើជាមួយញ៉ុម ញ៉ុមធ្វើជាមួយគាត់អីអញ្ចឹងទៅណាស់ជាមួយម៉ែញ៉ូមបងប្អូនញ៉ុមទាំងអស់អីអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈធ្វើលីកណ្ដាប់បោកបែនអីអញ្ចឹងទៅហើយអញ្ចឹងទៅដឹកជញ្ជូនមកផ្ទះ ដល់ពេលខែវស្សាទៀត ប៉ាញ៉ុមគាត់ឧជួលគេធ្វើភ្ជួរដីអញ្ចឹងហើយ យើងអត់មានគោអត់មានអីធំៗភ្ជួរទេណាស់មានតែគោញីអីទេ!!ជួលគេភ្ជួរអញ្ចឹងទៅ គាត់បាចស្រូវគាត់បាចស្រូវហើយមកទឹកឡើងអញ្ចឹងទៅវាមិនដុះ ភ្លៀងមក ស្រូវវាដុះ

ទឹកឡើងមកស្រូវហ្នឹងចេះតែហែលៗលើទឹកវារស់អញ្ចឹងទៅណាស់!!ដល់ពេលដល់ខែច្រូតអញ្ចឹងទៅនាំគ្នាទៅនេះអញ្ចឹងទៅ!!

កៈច្រូតស្រូវជុំគ្នា!!

ខៈ ច្រូតស្រូវជុំគ្នាអញ្ចឹងទៅណាស់!!

កៈចាំជាមួយបងជាមួយប្អូនដែរមីងហេ?

ខៈ ចាំជាមួយបងប្អូនអញ្ចឹងទៅហើយញ៉ុមហ្នឹងទូលបាយទូលអីបងប្អូនញ៉ូមគេទៅមុនអញ្ចឹងទៅហើយខ្ញុំអ្នកធ្វើបាយធ្វើអីរហ័សដីរហ័សជើងច្រូតបោកប៉ែនអញ្ចឹងទៅណាស់!! ហើយទៅដល់កន្លែងអញ្ចឹងទៅទៅដល់កន្លែងអញ្ចឹងទៅជញ្ជូនកណ្ដាប់គរអញ្ចឹងទៅ ខ្លាចមេឃ ខ្លាចអីភ្លៀងអញ្ចឹងទៅ!

កៈហ៊ឺៗ!!

ខៈអីអញ្ចឹងទៅណាស់!!

កៈចាំ!!

ខៈហ្នឹង!!

កៈសប្បាយណាស់មីង!!

ខៈ ថានេះនិយាយទៅនេះនិយាយកាត់ៗទេហ្ន៎នេះបើនិយាយតាំងពីប្រវត្តិអីនោះជូរចត់ណាស់វេទនាណាស់!!

កៈចាំ!!

ខៈទៅរកត្រីរកអី មានមងតែមួយដាក់អីវ៉ៃដាក់មកវ៉ៃ!!

កៈមីងចេះធ្វើទៀត?

ខៈ មងញ៉ូមយកទៅវាយ។

កៈចេះទៀត?

ខ៖ចាំ!!

ក៖ជិះទូកអីវ៉ាន់អញ្ចឹងទៅ?

ខ៖ ញុំមជួនកាលអត់ទូកទេ លុយទឹកដាក់មងវាយអញ្ចឹងទៅ!!ជាប់ត្រីស្មោរ

ក៖ ហ្ហ៎ទឹកអត់សូវជ្រៅអញ្ចឹងទៅហោ?

ខ៖ចាំ!!ដូចអត់សូវជ្រៅទេ ទឹករាក់ហ្នឹង!!

ក៖ហ្ហ៎!!

ខ៖ដាក់មងអញ្ចឹងទៅ បានមកស្លរអញ្ចឹងទៅ!!

ក៖អើរនិយាយទៅព្រែកឬក៏អី ឬក៏ប្រឡាយ?

ខ៖ អើយបឹង!! អត់មានព្រែកអត់មានអីទេ!!

ក៖បឹងហោ?

ខ៖ បឹងយើង!!

ក៖ តែសំបូរត្រីណាស់មឹងហីពេលមុន?

ខ៖ ចាំ!!ចំបក់មុនសំបូរត្រីណាស់!!ឥឡូវអស់ហើយ!!

ក៖ហើយដាក់មួយដៃអីហ្នឹងបានប៉ុន្មានគីឡូទៅមឹង?

ខ៖ដាក់មួយដៃបានត្រី ហោតាមចឹ!!តាមតិចតាមច្រើន!!

ក៖ម៉េចទៅ?

ខ៖ ពីរគីឡូពីរអីអញ្ចឹងទៅ។

ក៖ តែក៏សំបូរត្រី ស្ដីន ត្រីអីអញ្ចឹងទៅមឹងហោ?

ខ៖ បាន យើងដាក់ក្រឡាទូចយើងជាប់ត្រីទូច ដាក់ក្រឡាធំជាប់ត្រីធំដាក់ក្រឡាទូចៗហាំហើយកាលហ្នឹងដាក់អីចឹងទៅយកដំបងមួយអីចឹងទៅវ៉ៃ វ៉ៃទឹកអីចឹងទៅណាស់ វាទឹក!!

ក៖វ៉ៃដើម្បីអោយត្រីផ្អើល?

ខ៖វ៉ៃទឹកអោយត្រីផ្អើលជាប់អីអញ្ចឹងទៅណាស់ហើយដល់ពេលហើយ ដឹងម៉េចទេអត់ម្ហូបហូបហាំ!!

ក៖ហ៊ឺ!!

ខ៖ទៅច្រូតស្រូវអីចឹងអត់អីហូបអីចឹងហាំ យកមងមួយអាមងនេះហ្នឹងទៅកន្ទ្រប់វា ទៅកន្ទ្រប់អីចឹងទៅ!!

ក៖ហ៊ឺ!!

ខ៖ហើយដល់ហើយសង្កាត់ដៃអីចឹងទៅហើយជាន់អីចឹងទៅញ៉ុមថាជាន់ជើងខាងណោះជាន់ជើងខាង ណោះអីចឹងទៅ!!

ក៖ចាំ!!

ខ៖ ហើយសង្កាត់ហើយយកដៃរាវៗទៅរាវចាប់ត្រីអញ្ចឹងទៅណាស់!!

ក៖បានទៀត?

ខ៖ បានត្រីកន្ទ្រប់ត្រីអីអញ្ចឹងទៅ ចាប់អញ្ចឹងទៅ ដាក់ធុងអញ្ចឹងទៅ!!

ក៖ហ្ហ៊ូ!!

ខ៖ហ្នឹងបានអញ្ចឹងទៅ!! ហ៊ឺថាហឹបហ្នឹង!!

(ម្ដាយរបស់អ្នកមីង)៖ វានៅហ្នឹងគល់ហ្នឹង!!

ខ៖ វានៅនឹងគល់ហាំហើយយើងដាក់មងលើគល់ហ្នឹងទៅហើយយើងគ្របវាពីលើទៅ ហើយយើងយកជើងសង្កាត់ពីលើហ្នឹងទៅហើយយើងយកជើងយើងសង្កាត់សងខាងជើងយើងហ្នឹង!! !

ក៖ចាំ!!

ខ៖ហើយយើងយកដៃលូកចាប់ទៅចាប់!!

ក៖លូកទៅចាប់បានម៉ង!!

ខ៖ ហ្នឹងចាប់បាន!!

ក៖ ឥឡូវបើសាកធ្វើឥឡូវបើថាបាន!!!

ខ៖ចាប់អត់បានទេ ឥឡូវអត់មានគល់ដូចពីជំនាន់មុនហើយ!!ក៖ចាំ!!ខ៖រកតែខ្យងហូបមិនបានផងឥឡូវហ្នឹងហ្នំ!!

ក៖ហ្នឹងហើយ!!

ខ៖ ពេលមុនសំបូរត្រីណាស់!!

ក៖ តាមពិតហាំមីង ពេលមុនទោះក្រម៉េចក៏ដោយទោះពិបាកម៉េចក៏ដោយក៏មានត្រីហូបដែរមែនទេ?

ខ៖ ក៏មានត្រីហូបដែរ ក៏មានខ្យងហូបដែរ។

ក៖ហើយដល់ពេលឥឡូវអ្នកណាគេក្រអីវ៉ាន់ហាំគឺថាអើយមិនបាច់ថ្លែងម៉ងហើយណាស់មីងណាស់!!

ខ៖ អត់មានទេ!!

ក៖ ចាំ!!និយាយទៅវេទនាខ្លាំងម៉ងហ្នឹងហាំ!!

ខ៖ វេទនាម៉ងហាំមួយហឹកមុនវេទនាណាស់!!

ក៖ អូយនិយាយទៅ!!

ខ៖ ណោះនិយាយពីទៅធ្វើស្រូវធ្វើបាយធ្វើបន្លែ ទូលបាយ ទូលអាចមន៍គោទៀតណាស់ញ៉ុមប្រាប់ហ្មែង ទូលអាចមន៍គោហាំឡើងនេះលលាកក្បាលឡើងចង់អស់សក់ហើយនេះហិមើលសក់ញ៉ុមហិ!!

ក៖ ចាំ!!ឡើងចង់អស់សក់ឡើងស្តើង!!

ខ៖ សក់ញ៉ុមឡើងស្តើង ញ៉ុមប្រាប់ទៅ!!

ក៖ជំនាន់មុន ។

ខ៖ ធ្វើស្មៅហ្នឹងហា គូទមិនដែលបានស្អាតដូចគេទេ អាគូទខោហាំ និយាយពីឡើងជាប់កំពាស់មួយតឹកហើយសួរម៉ែញ៉ុមទៅបើមិនជឿ។

ក៖ ខំប្រឹងធ្វើការដើម្បីអនាគត ហាដើម្បីជីវភាព!!

ខ៖ ដើម្បីជីវភាពយើងតទៅមុខទៀត!!

ក៖ ហ៊ឺ!!

ខ៖ អ៊ីចឹងបានថាញ៉ុម!!

ក៖ អ៊ីចឹងចេះតែខំប្រឹងទៅមីងណោះ?

ខ៖ចាំ!!

ក៖ អ៊ីចឹងឥឡូវចូលដល់ជីដូនជីតា ហ៊ីមាននេះអីទៀតពីឪពុកមីងទេ គាត់ធ្វើការអីក្រៅពីស្រូវអីទៀតទេ?

ខ៖ ធ្វើស្រូវ ធ្វើបន្លែជាមួយញ៉ុមហ្នឹង!!

ក៖ បន្លែ ចាំ!!

ខ៖ ហើយហ្នួភ្លេចគាត់រត់ម៉ូតូទៀត រត់ម៉ូតូ រត់ស៊ីក្លូ មុនដំបូងរត់ស៊ីក្លូ ដល់ពេលស៊ីក្លូរត់អត់កើតរត់ម៉ូតូទៀត រត់ម៉ូតូរកមកចិញ្ចឹមកូនទំរាំបានអង្ករហូបយកមកដល់កាលហ្នឹងដូចថាថ្ងៃហ្នឹងដាច់ស្រូវអស់ស្រូវអស់ អ៊ីចឹងហាំ ដូចថាអត់បាននេះអ៊ីចឹង ដាច់ស្រូវដាច់អង្ករអ៊ីចឹងមកទំរាំតែបានគាត់មកដល់ផ្ទះម៉ោង៦អ៊ិចឹងណាស់បានបានលុយទិញអង្ករហូបក៏មានដែរ ហ្នឹងអ៊ីចឹង!!

ក៖ ចាំ តែមីងធ្វើស្រូវធ្វើអីដែរម៉េចអត់បានទុកអង្ករទុកអី?

ខះ តែថាអញ្ចេកថាយើងខ្វះខាតដូចថាអ្នកនៅក្នុងផ្ទះឈឺអីចឹងកូនឈឺដូចថាម៉ែញ៉ុមឈឺ កូនឈឺ!!

កះ ហ្នឹដូចថាលក់ស្រូវអស់!!

ខះ លក់ស្រូវអស់ទៅ!!

កះ ក៏អត់បានទុកហូបទៅ?

ខះទុកបានតែបន្តិចបន្តួចហូបទៅ ហើយដល់ពេលយើងឈឺយើងមិន!!

កះ កើបស្រូវយកទៅលក់។

ខះ បារស្រូវក្នុងជង្រុកយកទៅលក់អីចឹងទៅដល់ពេលយកទៅលក់ទៅអស់ស្រូវទៅអត់អង្ករហូបហើយដល់អីចឹងទៅបានគាត់រត់ម៉ូតូឌុប ហើយម៉ូតូវហ្នឹងសុទ្ធតែខ្ចីលុយគេចងការទៀត !!

កះហ៊ឺ!!

ខះយកទៅទិញម៉ូតូហ្នឹងហើយគាត់រត់ម៉ូតូហ្នឹងបានយកលុយហ្នឹងទិញអង្ករហូប!!

កះហ៊ឺ!!

ខះហ្នឹងម៉ោង៦ហើយបានញ៉ុមបានលុយទិញអង្ករហូបកាលហ្នឹងជំនាន់អ៊ុនតាក់ក្រមាទៅទិញដាក់ក្រមាហ្នឹង!!

កះចា៎!!!អញ្ចឹងពិបាកដែរហ្នឹងអញ្ចឹង!!ចា៎!

ខះថាទឹមតែឥឡូវទេមីអូនអើយ!!

កះ រៀងងើបតិចហើយមីងណោះ?

ខះ ចា៎រាងធូរបន្តិចហើយ!!និយាយពីរឿងឥឡូវហ្នឹង!!

កះចា៎ហើយអីចឹងអ្នកមីង!!

ខ៖ហើយទោះបីថាប្តីញ៉ុមប្តីចិនក៏មិនអោយញ៉ុមខ្វាកៗៗៗដែរ ចិនគំរិះណាស់ មុនហ្នឹងអោយសុទ្ធតែហុចអោយយើងអញ្ចេក អោយតិចតួចហាំ ហឺហេ ច្រលរអញ្ចឹងហ៎ថា អ្វូយថាញ៉ុមអត់ចង់បានពីគាត់ទេធ្វើម៉េចអោយប្រពន្ធកូនគាត់អោយបានសុខស្រួលទៅអោយ អោយកូនគាត់បានចាយ

អោយបានលុយចាយណោះទៅបានអោយញ៉ុមតិចតួចទៅកូនគាត់ធ្វើអញ្ចេកធ្វើអញ្ចឹងហាំ ថាញ៉ុមសើចអើយញ៉ុមសើចញ៉ុមអត់ខឹងទេ ញ៉ុមនឹកឃើញថាញ៉ុមកាន់ព្រះហាំញ៉ុមនឹកឃើញអញ្ចឹង មុននឹងអោយយើង៩ ១០រៀលអញ្ចឹង ធ្វើអញ្ចឹងហ៎!!

ក៖ហ៊ី!!

ខ៖ តែមើលអោយឃើញទៅផ្ទះហ្នឹងគាត់ធ្វើអោយយើងដែរ ធ្វើនេះប្រ៊កពិដានប្រ៊កអីអោយោយើងអីចឹងណាស់ តែតួផ្ទះញ៉ុមទេណាស់!!

ក៖ចាំ!!

ខ៖តួផ្ទះញ៉ុមទេកន្លែងពិដានហ្នឹងហើយធ្វើកន្លែងអាស្អីគេអាកន្លែងអាងទឹកនោះអោយដែរ កន្លែងលាងចានហ្នឹងអោយដែរ។

ក៖ចាំហ្នឹងហើយ!!

ខ៖អាហ្នឹងនិយាយអោយឃើញ ហើយឃើញអាទូនោះបានមួយដែរ អាទូទឹកកកហ្នឹងនិយាយ អោយឃើញ!!

ក៖ហ៊ីចាំ!!

ខ៖ហើយញ៉ុមថាអញ្ចេកហ៊ីញ៉ុមអត់ចង់បានទេ គាត់អោយមិនអោយទៅបើមិនអោយក៏ញ៉ុមអត់ថា អត់ខឹងអត់សម្បាអីទេ ព្រោះអីគេគេមានកូន មានកូននៅចិនណាស់ គាត់ប្រាប់ដែរ គាត់ថាអញ្ចេកគាត់អត់ទេ គាត់ស្តីញ៉ុមហ្នឹង បើយកគាត់ក៏យកទៅមិនយកក៏ហីទៅ!! ញ៉ុមថាអញ្ចេកអត់សំខាន់ទេរឿងលុយញ៉ុមនិយាយអីចឹងហាំ!!

ក៖ហ៊ី!!

ខ៖ ញ៉ុមនិយាយថាអត់សំខាន់ទេរឿងលុយ សំខាន់អោយតែស្រលាញ់គ្នាប្តីប្រពន្ធស្រលាញ់គ្នា!!

កៈហឺ!!

ខៈដល់ពេលហើយគាត់ថាអញ្ចេកគាត់មានប្រពន្ធតែប្រពន្ធគាត់តែទៅតែមកថាអោយប្តីគាត់ហ្នឹងយកប្រពន្ធហ្នឹងនៅស្រុកខ្មែរទៅណាស់ ញ៉ុមថាអត់យកទេប្តីគេ ញ៉ុមអត់យកទេ!!

កៈហឺ!!

ខៈ ដល់ពេលហើយទៅអ្នកនៅធ្វើការហ្នឹងគេថាអញ្ចេក ហើយនឹងបងប្អូនញ៉ុមអីវ៉ាន់ថាហ្អែងយកទៅតែអត់យកអត់ប្តីអត់កូន តែបើគេទៅស្រុកនឹងជាយើងបានកូនមើលយើងចាស់តែគំនិតញ៉ុមអត់យកទេ
ញ៉ុមនឹកឃើញថាចាស់ទៅញ៉ុមនៅតែឯងនៅជាមួយបងប្អូនអីអឺចឹងទៅណាស់!!

កៈហឺ!!

ខៈដល់ពេលហើយទៅបានបានបងប្អូនញ៉ុមអីថាប្អូនញ៉ុមថាអញ្ចេក ជ្រៀចឯងតែអត់យកហាំចាស់ទៅវេទនាហើយនៅម្នាក់ឯង !!

កៈហឺ!!

ខៈដល់ពេលហើយបងប្អូនញ៉ុមជីដូនមួយថាអញ្ចេកហ៊ឺហ្អែងអត់យកហាចាស់ទៅវេទនាហើយ
ចាស់ទៅលុយក៏អត់ដីក៏អត់ដីក្រោយមានតែក្រោយផ្ទះទេ អត់យកប្រយត្ន័ទៅប្រយត្ន័វេទនាប្រយត្ន័អត់មានទឹកក្តៅទឹកត្រជាក់ហើយប្រយត្ន័អត់មានបាយស៊ី!!

កៈហឺ!!

ខៈ ហើយគេបងប្អូនគេរករង្វះរង្វាល់កូនចៅគេហាំ!!

កៈ ហឺៗ!!

ខៈហើយគេនិយាយអញ្ចឹងញ៉ុមភ្ញាក់ខ្លួនញ៉ុមយកទៅ !!

កៈហឺ!!

ខៈញ៉ុមនឹកឃើញថាអឺមែនគេនិយាយត្រូវហើយ
ញ៉ុមយកមកញ៉ុមដេកគិតឡើងមួយខែជាងបានញ៉ុមយកហាំ!!

កៈចាំ!!

ខៈដល់ពេលហើយទៅបានអាកុងញ៉ុមហ្នឹងសួរញ៉ុមប្រហែលជាពីរខែហើយហើយញ៉ុមយកមកដេកគិតមើលសិនទាល់ពេលញ៉ុមយកពីរ បីខែបានញ៉ុមយកហាំ!!

កៈហ៊ឺ!!

ខៈ ដល់ពេលហើយបានញ៉ុមជឿតាមជីដូនមួយញ៉ុមនៅណោះនៅភ្នំពេញបងប្អូនញ៉ុមអីនៅស្រុកញ៉ុមហ្នឹងឈ្មោះតី ឈុន ហ្បែងយកទៅ ហ៊ីយកទៅដល់ពេលហើយថាអញ្ចេកប្ដីគេនឹងជា តែប្រពន្ធគេអោយយកប្រពន្ធនៅស្រុកខ្មែរគេខ្លាចទៅយកស្រីខូច ខ្លាចកើតអេដស៍ ស្ដាប់អោយទាន់ហាំដល់ហើយខ្ញុំណោះក៏យកទៅហើយកូនគេណោះថាអញ្ចេកក៏គេថាអត់អីដែរតែប្រពន្ធគេតេមកញ៉ុមហើយមកថា!!

កៈហើយនិយាយគ្នាម៉េចទៅបើចិនហ្នឹង?

ខៈ ញ៉ុមអត់និាយយទេតែមានអ្នកបកប្រែ ចាំមើលញ៉ុមនិយាយហាំគាត់ចេះអញ្ចេកបើយកគាត់ក៏យកទៅ
មិនយកគាត់ក៏ហឺទៅតែគាត់ថាគាត់អត់លុយទេគាត់អោយ២៥០ហ្នឹងរៀបទៅ
អោយ១០០ក៏ញ៉ុមអត់ថាអី
អោយ២៥០ក៏ញ៉ុមអត់ថាអីអោយតែអោយលុយរៀបអោយសមរម្យអោយគេដឹងឮអីអញ្ចឹងទៅណាស់អោយចាស់ទុំដឹងឮ
ហើយរៀបទៅ!!កៈហ៊ឺ!!ខៈរៀបទៅដល់ពេលហើយទៅដូចថារៀបហើយអីហើយអញ្ចឹងគាត់ថាគាត់អត់មានលុយទេកូនគាត់រៀន ញ៉ុមថា ក៏ញ៉ុមអត់ថាអីដែរអត់ថាអីទេ!!កៈចាំ!!ខៈតែគ្រាន់តែថាអញ្ចេកឈឺអីអញ្ចឹងហាំ កូនញ៉ុមឈឺអីអញ្ចឹងហាំដូចថាអើយទៅសុំគាត់៥ ១០ ២០រៀលអីអញ្ចឹងទៅណាស់សំរាប់កូនញ៉ុមឈឺហាំ!!

កៈតែគាត់ឥលូវគាត់នៅរោងចក្រមែនមីង?

ខៈ គាត់ទៅរោងចក្រគាត់ទឹមតែទៅដែរហ្នឹង!!

កៈ ហ្ហ៎ !! ឥឡូវឈប់សិនកុំទាន់អាលនិយាយរឿងប្ដី!!

ខ៖ចាំ!

ក៖ចាំតិចទៀតចាំនិយាយរឿងប្ដីឥលូវនិយាយរឿងម៉ែឪអោយអស់សិន ឥលូវចូលដល់ជីដូនជីតាវិញខាងឪពុក យាយឈ្មោះអីគេខាងឪពុក?

ខ៖ ខាងប៉ាញ៉ុមហោ?

ក៖ចាំ!!

ខ៖ ឈ្មោះយាយសេក។

ក៖ យាយសេកហោ?

ខ៖ យាយសេកតាហោ!!

ក៖ ចាំអញ្ចឹងនៅក្នុងសំបុត្រកំនើតរបស់ឪពុកអ្នកមីងគាត់ឈ្មោះម្ដាយគាត់ឈ្មោះ នូ សេក។

ខ៖ចាំ!!

ក៖ សញ្ជាតិខ្មែរកើតនៅក្នុងឆ្នាំ១៩១១ ចាំ ពួកគាត់កើតនៅក្នុងភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាលដែរ!!

ខ៖ចាំ!!

ក៖ អ៊ីចឹងបងប្អូនមីងសុទ្ធតែកើតនៅហ្នឹងដែរទាំងអស់គ្នា?

ខ៖នៅហ្នឹងទាំងអស់គ្នា!!

ក៖ចាំ!! មីងកើតទាន់យាយសេកទេ?

ខ៖ទាន់តើ!!

ក៖ គាត់ម៉េចដែរមីងអាចនិយាយប្រាប់ពីយាយសេក!!

ខ៖ ហ្នឹងខាងប៉ាញ៉ុមទាន់!!

ក៖ចាំ!!

ខ៖ គាត់អើយមនុស្សគាត់អើរល្អ ល្អ!!

ក៖ចាំ!!

ខ៖ មនុស្សគាត់ដូចថាស្លូតបូត គាតល្អយាយញុំមល្អ តែយាយខាងម៉ែញុំមអត់ទាន់ទេ!!

ក៖ហ៊ឹៗ!!

ខ៖អត់ទាន់ទេ !!

ក៖ចាំ!!

ខ៖អត់ទាន់!!

ក៖តែដឹងតែយាយសេកគាត់ស្លូតបូតល្អត្រឹមត្រូវ!!

(ម្ដាយរបស់អ្នកមីង)៖ គាត់ស្លូតទាំងអស់។

ខ៖ គាត់ស្លូតណាស់ តាញុំមក៏ស្លូត!!

ក៖ គាត់ធ្វើការអីគេវិញអ្នកមីង?

ខ៖ គាត់អើយធ្វើចំការ។

ក៖ ចំការដែរ?

ខ៖ ចាំស្រែចំការ តែគាត់ស្លាប់តាំងពីជំនាន់បែកអាពតហើយ។

ក៖ហ្អ៎!!

ខ៖ញុំមទាន់គាត់!!

ក៖ចាំ!!

ខ៖ហ្នឹងហើយ
ហើយពេលម៉ែខ្ញុំមកពីលក់ឃ្មុំលក់អីអញ្ជឹងណាស់មកពីណាអីអញ្ជឹងបាននំបានអីអញ្ជឹងយកមកអោយគាត់ហាំ!!

កៈ អញ្ចឹងអ៊ំធ្លាប់លក់ឃ្មុំដែរ?

ខៈ លក់ឃ្មុំដែរពេលជំនាន់មុន!!

កៈហ្ហ៎!!

ខៈរកស៊ីលក់ឃ្មុំពេលជំនាន់មុន!!

កៈ ឃ្មុំអីវ៉ាន់ជំនាន់មុនសុទ្ធៗណាស់!!

ខៈ ចា៎!!

កៈ មីងដឹងម៉េចទេឃ្មុំហា៎ទិញទាំងផ្លិតអ៊ំយកមកច្របាច់សោះហ្នឹងហា៎ មីងដល់ពេលទុកបានប៉ុន្មានថ្ងៃទៅកក កកស្ករ គេបាញ់ទឹកស្ករចូលទៅក្នុងឃ្មុំ!!

ខៈ ទឹកស្ករទេកុំ!!

(ម្តាយអ្នកមីង)៖ ឃ្មុំវាអត់សុទ្ធ!!

កៈ ចា៎ ពេលមុនគេធ្វើអីត្រង់ៗសុទ្ធៗល្អណាស់!!

ខៈ គេបាញ់ទៅស្ករ!!

កៈ ចា៎ តែដល់ពេលឥលូវមិនបាច់ទេមីងអើយមិនបាច់លូកហើយថ្លៃទៀត ទឹកស្ករអោយឯងសោះលក់សុទ្ធតែមួយលីត្រ១០០០០០ជាង!!

ខៈហ៊ឺ!!

កៈ ចង់រយែកទ្រូង!!

ខៈ កុំ កុំ ស្លរញ៉ុមបើទិញអត់ស្លរញ៉ុម!!

កៈហ៊ឺ!!មីងនៅនេះគេមានលក់ឃ្មុំសុទ្ធៗដែរហេ?

ខៈ មានតែណោះខាងណោះ!!

កៈហ្ហ៎!!

ខ៖ខាងណោះ!!

ក៖ អញ្ចឹងបើចង់ទិញឃ្មុំអីចាំមកទិញខាងណោះវិញ!!

ខ៖ មានខែ១ ខែ២ហ្នឹងហ៊ា ខែហ្នឹងកំពុងតែពេញមានហើយ!!

ក៖ចាំ!! មួយលីត្រប៉ុន្មានមីងនៅណោះ ?

ខ៖ ហោអត់មានទឹកទេម៉ែហោ?

(ម្ដាយរបស់គាត់)៖ ហាំ??

ខ៖ អត់មានទឹកទេហោ?

(ម្ដាយអ្នកមីង)៖ ទឹកអី?

ខ៖ ទឹកឃ្មុំ!!

(ម្ដាយអ្នកមីង)៖ មានតែនៅស្រុកគេ !!

ក៖ មួយលីត្រប៉ុន្មានអ៊ំនៅណោះ?

(ម្ដាយរបស់អ្នកមីង)៖ ៣០០០០ ៤០០០០អីហ្នឹង។

ក៖ អូយថោកម្ល៉េះ?ទឹកឃ្មុំនៅណោះតែ៣០០០០ ៤០០០០ទេចុះ?

(ម្ដាយរបស់អ្នកមីង)៖ ចាំ!!

ក៖ ថោកអ៊ំ!!!

(ម្ដាយរបស់អ្នកមីង)៖ ទឹកថ្លៃ!!

ក៖ អាសុទ្ធ!!

(ម្ដាយរបស់អ្នកមីង)៖ មិនដឹងឥលូវគេលក់ប៉ុន្មានទេ កាលញុំមលក់៣០០០០ ៤០០០០ហាំ!!

ក៖ ហ្ហ៎សម័យមុន៣០០០០ ៤០០០០តែឥឡូវមិនស្រួល១០០០០០ណោះហី?

ខ៖ ចាំ!!

ក៖ និយាយទៅអោយតែបានសុទ្ធ វាជួយសុខភាពច្រើនណាស់មីងណាស់!!

ខ៖ចាំ!!

ក៖ ចាំអញ្ចឹងតា តាឈ្មោះអីគេ?តាខាងឪពុក?

ខ៖ តាហោ។

ក៖ តាហោ!!

ខ៖ តាហោ យាយសេក!!

ក៖ ចាំអញ្ចឹងនៅក្នុងសំបុត្រកំនើត ឈ្មោះម៉ី ហោ!!

ខ៖ចាំ!!

ក៖ សញ្ជាតិខ្មែរកើតនៅក្នុងឆ្នាំ១៨៩៥!!ចំ!!និយាយទៅគាត់ចំណាស់ដែរហើយហ្នឹង កើត១៨៩៥ ចំបងរបស់យាយច្រើនឆ្នាំដែរ!!

ខ៖ចាំ!!

ក៖ ១០ឆ្នាំចង់២០ឆ្នាំហើយនេះ នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា ហ្នឹងតាហោ!!

ខ៖ចាំ!!

ក៖ មីងកើតទាន់តាហោទេ?

ខ៖ ទាន់តើតាញ៉ុម។

ក៖ ម៉េចដែរគាត់ មីងនិយាយពីគាត់មើល?

ខ៖ ហ្នឹង គាត់ស្រួល ដូចថាដឹងតែធ្វើ ធ្វើចំការ!!ដឹងតែពីរ ដូចថាមកផ្ទះអីចឹងទៅជួយធ្វើការងារប្រពន្ធកូនអីអីចឹងទៅណាស់!!

កៈចាំ!!

ខៈតែបើតាយាយខាងម៉ែអត់ទាន់ទេ។

កៈហ៊ឺ!!

ខៈត្រឹមតាញ៉ុមហ្នឹងក៏ញ៉ុមអត់ទាន់ដែរ។

កៈ ចាំអញ្ចឹងទាន់បានខាងឪ។

ខៈ ទាន់បានតែខាងឪ!!

កៈចាំអ៊ីចឹងគាត់សុទ្ធតែជាមនុស្សល្អមីងណោះ?

ខៈ គាត់សុទ្ធតែជាមនុស្សល្អ!!

កៈ ចាំ!!

ខៈ នោះពូស្រួច គាត់ចូលសាសនាដែរហ្នឹង!!

កៈ អ៊ីហ្នឹងពូស្រួច?

ខៈ ពូស្រួចហ្នឹង!!

កៈចាំ!!

ខៈឥឡូវគាត់ឈឺ។

កៈ ហ្នឹងហើយចាំហើយ!! ពូស្រួចផ្ទះនៅឯណាវិញ?

ខៈ ចាំនៅភូមិថ្មីហ្នឹង!!

កៈចាំ!!អសកម្មអស់ច្រើនណាស់ នៅភូមិកោះគរឥឡូវ!!

ខៈចាំ!!

កៈ អ៊ីចឹងអ្នកមីងសំរាប់ឥឡូវចូលដល់ខាងយាយវិញម្ដង ខាងម៉ែគាត់ឈ្មោះយាយអីគេវិញ?

ខ៖ យាយ យាយខាងម៉ែហោ?

ក៖ចា៎!!

ខ៖ យាយឆាំ។

ក៖ ហ្នឹងហើយឈ្មោះ រស់ ឆាំ នៅក្នុងសំបុត្រកំណើតដាក់ឈ្មោះរស់ ឆាំ កើតនៅក្នុងឆ្នាំ១៩២៧ នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា!!អញ្ចឹងមីងកើតទាន់យាយឆាំទេ?អត់ណាហី?

ខ៖ អត់ទាន់ទេយាយញ៉ុមស្លាប់បាត់ហើយ ពេលញ៉ូមកើតមក។

ក៖ ចុះដែលម៉ែប្រាប់អីពីយាយខ្លះអត់?

ខ៖ គាត់ប្រាប់ថាយាយញ៉ុមវេទនាណាស់ អត់បាយ!!

ក៖ ម៉េចវិញ?

ខ៖ អត់បាយកាលពេលជំនាន់ហ្នឹងហ្វ៎!!

ក៖ ជំនាន់ប៉ុល ពតហ្នឹងហោ?

ខ៖ ជំនាន់ប៉ុល ពតហ្នឹងមែនទេម៉ែ? ហ្នឹងជំនាន់ហ្នឹង ជំនាន់ប៉ុល ពតហ្នឹង!!

ក៖ លំបាកវេទនាម៉ង!!

ខ៖ លំបាកវេទនាណាស់ គាត់ទៅស្លាប់នៅណានៅបាត់ដំបងហ្នឹង។

ក៖ហ្វ៎ដោយសារអត់បាយហ្នឹងបានស្លាប់នៅក្នុងជំនាន់ប៉ុល ពតហោ?

ខ៖ ចា៎អត់បាយ!!

(ម្ដាយរបស់អ្នកមីង)៖ ហ្វ៎!ម្ដាយញ៉ុមស្លាប់នៅបាត់ដំបងហ្វ៎!!!

ក៖ ហ្វ៎ស្លាប់នៅបាត់ដំបងអំណោះ?

(ម្ដាយរបស់អ្នកមីង)៖ ចាំ ហើយយាយញ៉ុម តាញ៉ុមឪពុកក្មេកញ៉ុម ខាងតានេះគាត់ស្លាប់នៅនេះទេ(ខាងប្ដីរបស់គាត់)។

ក៖ នៅកោះគរនេះទេ?

(ម្ដាយរបស់អ្នកមីង)៖ ចាំ!!!

ក៖ អូយពិបាកដែរហ្នឹងហាំ !!

ខ៖ចាំ!!

ក៖អ៊ីចឹងប្រវត្តិជូរចត់ណាស់អារឿងខាងសង្គ្រាមហ្នឹង ។ហើយដល់ពេលតាហាហ្នឹងតាអីគេវិញ?

ខ៖ តាអើយញ៉ុមកើតអត់ទាន់គាត់។

ក៖ កើតអត់ទាន់គាត់ទេហេ គាត់ស្លាប់នៅក្នុងជំនាន់ប៉ុល ពត!! ហ៊ីទាន់តើមីង បើគាត់ស្លាប់នៅក្នុងជំនាន់ប៉ុល ពតមីងកើតទាន់តើ!!

ខ៖ ទាន់ តែអត់បានឃើញមុខគាត់អី!!

ក៖ ដូចថាមីងនៅក្មេងពេកហេ?

ខ៖ នៅក្មេងពេកញ៉ុមស្គាយអត់ទាន់តាញ៉ុម!!

ក៖ចាំ!!

ខ៖ ស្ដាយណាស់អត់ទាន់គាត់ទេ!!ក៖ចាំ!!

(ម្ដាយរបស់អ្នកមីង)៖ វានៅទូចៗហ្នឹងហេ!!

ក៖ ហ្នឹងហើយ!! ចាំអ៊ីចឹងនៅក្នុងសំបុត្រកំណើតតាអ្នកមីងឈ្មោះសួសធុច!!

(ម្ដាយរបស់អ្នកមីង)៖ ធុយ។

ក៖ ធុយ!! អីយ៉ាស់ច្រឡំធុច!! ឈ្មោះតា យូស ធុយ!!

ខ៖ចាំ!!

កៈ កើតនៅក្នុងឆ្នាំ១៩២៥នៅភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា!!

ខៈចាំ!!

កៈ អញ្ចឹងសុទ្ធតែអ្នកនៅកោះគរហ្នឹងទាំងអស់។

ខៈ កោះគរទាំងអស់!!

កៈ អញ្ចឹងថ្ងៃហ្នឹងដូចជាបានប្រវត្តិគាត់ទាំងអស់បានឡើងម៉ាពេញបិបម៉ងណេះ!!

ខៈចាំ!!

កៈណេះសុទ្ធតែឆ្នាំអីវ៉ាន់នៅក្នុងសំបុត្រកំនើតទុកមើលអីវ៉ាន់អីចឹងទៅមីងណាស់!!

ខៈ ចាំ!!

កៈ ចាំអីចឹងអ្នកមីងម៉ែមានដែលប្រាប់ថាតាធុយម៉េចៗអីខ្លះអីអត់?

ខៈ អើយប្រាប់ថាពេលអើរគាត់ស្លាប់ទៅអត់មានអីហូបអីអញ្ចឹងទៅណាស់!!

កៈ អត់មានអីហូបដែរ?ដូចប្រពន្ធដែរអីចឹង?

ខៈ ចាំ!!គាត់អត់មានអីហូបហ្នឹងហាំ!!

កៈអ៊ំទាំងពីរនាក់ម៉ែឪអ៊ំស្លាប់ដោយសារអត់កមានបាយហូបទាំង២?

(ម្ដាយរបស់អ្នកមីង)៖ ចាំ អត់មានបាយហូប។

ខៈ អត់មានបាយហូបទាំង២!! ហ្នឹងញ៉ុមលឺសូរម៉ែញ៉ុមនិយាយអីចឹង!!

កៈ និយាយថាតាស្លាប់មុនឬក៏យាយស្លាប់មុន?

(ម្ដាយរបស់អ្នកមីង)៖ អើរតាស្លាប់មុន។

ខៈ តាស្លាប់មុន។កៈ ហ្ហ៎!!

(ម្ដាយរបស់អ្នកមីង)៖ ម្ដាយញ៉ុមអត់មានបាយទេហូបតែកន្ទក់ទេ។

ខ៖ កន្ទក់ហ្នឹងហើយគល់ចេកហ្នឹង!!

(ម្ដាយរបស់អ្នកមីង)៖ ហើយគល់ចេក។

ក៖ អើយវេទនាណាស់!! វាមិនអោយស៊ីពួកអាប្រេតអត់ហ្នឹង ហ៊ី៖!!ចាំអញ្ចឹតងគាត់ស្លាប់ដោយសារនៅក្នុងជំនាន់ប៉ុល ពត មីងមានចាំអីទៀតពីតាអីអត់ចង់និយាយអីចឹងណាស់?

ខ៖ អើរលើសូរម៉ែញ៉ុមនិយាយថាគាត់អត់មានអីហូបអិចឹងណាស់ ញ៉ុមចាំតែប៉ុណ្ណឹង!!

ក៖ ចាំតែប៉ុណ្ណឹងតើហី?

ខ៖ចា៎!!ចាំតែប៉ុណ្ណឹង!

ក៖ អត់មានអីផ្សេងទៀតទេហី?

ខ៖ តែអូសកាលជំនាន់ថា កាលជំនាន់លន់ នល់ដឹងអីមិនដឹតងទេថា កាលហ្នឹងគាត់លក់គុយទាវលក់អីដែរតើ!!

ក៖ហ្ហ៎!!

ខ៖ គាត់លក់គុយទាវដែរតើ!!

ក៖ហ្ហ៎បើកហាងគុយទាវអីដែរហោ?

ខ៖ ចា៎បានលក់គុយទាវអីដែរ។

ក៖ គិតទៅមនុស្សធ្លាប់ហូបធ្លាប់អីឆ្ងាញ់អីវ៉ាន់អាពេល!!

ខ៖ គាត់លក់ លក់គុយទាវអាពេល លក់គុយទាវពោះគោហើយកាហ្វេ អិចឹងបានម៉ែញ៉ុមតំណាងលក់កាហ្វេហា៎!!

ក៖ ចា៎ ចេះតែតៗគ្នា!! អញ្ចឹងនៅក្នុងសៀវភៅគ្រួសាររបស់អ្នកមីងមានឈ្មោះបងប្អូនឪពុកម្ដាយអីចឹង អ្នកមមីងមានឈ្មោះ អីចឹងអ្នកខ្លះកាត់ចេះហើយហ្នឹង កាត់ឈ្មោះចេញមីងណា?

ខ៖ កាត់ឈ្មោះចេញមីងច្រើប!!

កៈ មីងច្រឹបហោ?ខ

ខៈ ចាំមីងច្រឹប!!ហើយញ៉ុមអត់ទានកាត់ចេញផង!

កៈ ចាំ!!អញ្ចឹងស្រី ជ្រៀម !!អីចឹងប្អូនអ្នកមីងឈ្មោះស្រីជ្រៀមអ្នកមីងណោះ?

ខៈ ខ្ញុំឈ្មោះស្រី ជ្រៀម!ខ្ញុំហ្នឹងហើយ!!

កៈ ហ្ហ៎មីងទេ មីងទេ!!

ខៈ ស្រី ជ្រៀច។

កៈ អីចឹងមីង ចាន់ថា!! ហើយមួយទៀតឈ្មោះ ស្រី រតនា មីងណោះ?

ខៈ ចាំហ្នឹងហើយប្អូនពៅ!!

កៈ អញ្ចឹងក៏កើតនៅកោះគេហ្នឹង ស្រុកស្អាងខេត្តកណ្តាលយើងហ្នឹងដែរ!!អញ្ចឹងថ្ងៃខែឆ្នាំកំនើតរបស់គាត់អត់មានឃើញផងហ្នឹង!!មើលអត់ឃើញទេ!!

ខៈចាំ!!

កៈអីចឹងអត់មានដាក់កើតអត់មានដាក់អីផង
អូខេដោយសារងងឹតៗមើលអត់ឃើញ។ហើយអញ្ចឹងអ្នកមីង
អ្នកមីងមានចង់ប្រាប់អីពីដូនតាឬក៏មានអីដែលចង់ប្រាប់ទៀតឬមួយក៏អត់?

ខៈ ចង់រៀបរាប់ថាឪពុកញ៉ុមដូចថាពិបាក ពិបាកដូចថាពីមុនៗមកពិបាកវេទនាអីចឹងហាំ!!

កៈហ៊ឹៗ!!

ខៈទំរាំបានមកដល់ឥឡូវរៀងធូរបន្តិចរៀងគ្រាន់បន្តិច ពីមុនមកវេទនាណាស់!

កៈ ចាំពិបាកម៉ងហោមីង?

ខៈ ដូចថាប៉ាញ៉ុមឈឺ ខ្វីលុយខ្វីអីគេអញ្ចឹងណាស់ លើកពីនេះដាក់នោះ លើកពីនោះដាក់នេះ ថាអត់វេទនាម៉ងបើនិយាយរួមទៅបានទឹមតែឥឡូវបានរៀងគ្រាន់បន្តិច។

កៈចាំ!!

ខៈ រៀងប្រើសៗបន្តិចហើយណាស់!!

កៈហ៊ឺៗ!!

ខៈរៀងធូរតិចៗៗទៅ!!

កៈ ចាំអញ្ចឹងជីវិតរបស់អ្នកមីងនឹងគ្រួសារវាជួបរឿងជូរចត់ដែរ!!

ខៈ ហើយទៅធ្វើការធ្វើអីនៅតាខ្មៅជួលផ្ទះជួលអីគេដេកទៀត ។

កៈហ៊ឺ!!

ខៈ ហើយទៅហើយពីរនាក់ប្អូនញ៉ុមហ្នឹង ហ្នឹងសុទ្ធតែយកលុយរដ្ឋបើយើងមិនខំប្រឹងវាអត់កើតវាពិបាក!!

កៈ វាពិបាកអីចឹងមីងណោះ?

ខៈចាំ វេទនាណាស់!!

កៈ
អីចឹងអរគុណច្រើនអ្នកមីងសំរាប់អោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមិងក៏ដូចជាពីដូនតានឹងដំនើរជីវិតរបស់អ្នកមីង !!

ខៈ ហ្នឹងត្រូសៗទេណាស់ ខ្លីៗហ្នឹង។

កៈ ចាំអញ្ចឹងអរគុណច្រើនណាស់មីង។